# កប្បដ្ឋិយចាដិហារ្យ

(ចាដិហារ្យដែលតាំងនៅអស់កប្ប)



**ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា**

**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

*រៀបរៀងដោយ*

*ខ្ញុំព្រះករុណាខ្ញុំបាទ*

**កុល ផេង** **ព.ស. ២៥៦២**



**ឯវំ អចិន្តិយា ពុទ្ធា, ពុទ្ធធម្មា អចិន្តិយា,**

**អចិន្តិយេ បសន្នានំ, វិបាកោ ហោតិ អចិន្តិយោ**

*ព្រះពុទ្ធទាំងឡាយជាអចិន្តិយបុគ្គល*

*ធម៌របស់ព្រះពុទ្ធជាអចិន្តិយធម៌ យ៉ាងនេះ*

*កាលបុគ្គលជ្រះថ្លាចំពោះគុណជាអចិន្តិយៈ*

*រមែងបានផលជាអចិន្តិយៈ ។*

# កប្បដ្ឋិយបាដិហារ្យ ៤

## (បាដិហារ្យដែលតាំងនៅអស់កប្ប)

**១. ចន្ទេ សសលក្ខណំ សកលម្បិ ឥមំ កប្បំ ឋស្សតិ** *រូបទន្សាយក្នុងព្រះចន្ទ្រ នឹងតាំងនៅអស់កប្ប នេះ សូម្បីទាំងមូល ។*

**២. វដ្ដកជាតកេ អគ្គិនោ ជិព្ពុតដ្ឋានំ សកល-ម្បិ ឥមំ កប្បំ អគ្គិ ន ឈាយិស្សតិ** *ភ្លើងរមែងមិនឆេះ នូវកន្លែងដែលរំលត់ភ្លើង ក្នុងវដ្តកជាតក អស់មួយកប្ប នេះ សូម្បីទាំងមូល ។*

**៣. ឃដីការនិវេសនដ្ឋានំ សកលម្បិ ឥមំ កប្បំ អនោវស្សកំ ឋស្សតិ** *ភ្លៀងមិនស្រក់ចុះស្ថាន ទីជាលំនៅរបស់ឃដីការស្មូនឆ្នាំង នឹងឋិតនៅអស់មួយ កប្ប សូម្បីទាំងមូល ។*

**៤. ឥមំ បោក្ខរណឹ បរិវារេត្វា ឧដ្ឋិតនឡា សកលម្បិ ឥមំ កប្បំ ឯកច្ឆិទ្ទា ភវិស្សន្តិ** *ដើមបបុស ដែលដុះនៅជុំវិញស្រះបោក្ខរណីនេះ នឹងជាដើមមានថ្នាំងតែមួយអស់មួយកប្ប សូម្បីទាំងមូល ។*

*(អដ្ឋកថា ជាតក ឯកកនិបាត សីលវគ្គ នឡបានជាតក)*

# ១. សសបណ្ឌិតជាតក

## (រូបទន្សាយក្នុងព្រះចន្ទតាំងនៅអស់កប្ប)

*ព្រះសាស្តា កាលស្តេចគង់នៅ វិហារជេតវន ទ្រង់ប្រារព្ធ ការថ្វាយបរិក្ខារគ្រប់យ៉ាង ទើបត្រាស់ព្រះធម្មទេសនានេះ មានផ្តើមថា* **សត្ត មេ រោហិតា មច្ឆា** *ដូច្នេះជាដើម ។*

*បានឮថា ក្នុងក្រុងសាវត្ថី មានកុដុម្ពិកៈម្នាក់ ត្រៀមការថ្វាយបរិក្ខារទាន គ្រប់យ៉ាង ដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន បានឲ្យគេសាងមណ្ឌប ត្រង់ទ្វារផ្ទះ ហើយនិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធ ជាប្រធាន ឲ្យគង់លើអាសនៈដ៏ប្រសើរ ក្នុងមណ្ឌប ដែលបានចាត់ចែងល្អហើយ បានថ្វាយទានដ៏ប្រណីត មានរសដ៏ល្អផ្សេងៗ ហើយនិមន្តឲ្យឆាន់រហូត ៧ ថ្ងៃ ក្នុងថ្ងៃទី ៧ បានថ្វាយបរិក្ខារទាំងពួង ដល់ភិក្ខុ ៥០០ មានព្រះពុទ្ធ*

ជាប្រធាន ។ ក្នុងវេលាធ្វើភត្តកិច្ចហើយ ព្រះសាស្តា កាលទ្រង់នឹងធ្វើអនុមោទនា ទើបត្រាស់ថា ម្នាល ឧបាសក អ្នកគួរធ្វើបីតិសោមនស្សចុះ ឈ្មោះថា ទាន នេះជាវង្ស របស់បោរាណបណ្ឌិត ទាំងឡាយ ព្រោះថា បោរាណបណ្ឌិតទាំងឡាយ បានបរិច្ចាគជីវិត ដល់ យាចក អ្នកមកដល់ចំពោះមុខ សូម្បីជីវិតរបស់ខ្លួនក៏ បានឲ្យហើយ ។ ឧបាសកនោះ ក៏ក្រាលទូល អារាធនា ទើបទ្រង់នាំអតីតនិទានមកជាសាធក:ដូចតទៅថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្ត សោយ រាជសម្បត្តិ ក្នុងនគរពារាណសី ព្រះពោធិសត្វបាន កើតក្នុងកំណើតសត្វទន្សាយ នៅក្នុងព្រៃ ។ ក៏ក្នុងព្រៃ នោះ មានដើមភ្នំ ទន្លេ និងបច្ចន្តគ្រាម មករួមគ្នាត្រង់ កន្លែងមួយ ។ សត្វសូម្បីដទៃ ៣ ទៀត គឺ ស្វា ឆ្កែចចក និងភេ បានជាសម្លាញ់របស់ទន្សាយនោះ ។ សត្វសូម្បី ទាំង ៤ នោះ ជាបណ្ឌិតនៅរួមគ្នា កាន់យកចំណីក្នុងទី

ជាទីគោចរ របស់ខ្លួនៗ ហើយមកប្រជុំគ្នា ក្នុងវេលាល្ងាច ។ សសបណ្ឌិតសម្ដែងធម៌ ដោយការឲ្យឱវាទដល់សត្វទាំង ៣ ថា គប្បីឲ្យទាន រក្សាសីល និងធ្វើឧបោសថកម្ម ។ សត្វទាំង ៣ នោះទទួលឱវាទរបស់សសបណ្ឌិតនោះហើយ ចូលទៅកាន់គុម្ពឈើដែលជាទីអាស្រ័យរបស់ខ្លួនៗ ។ កាលកន្លងទៅយ៉ាងនេះ ក្នុងថ្ងៃមួយ ព្រះពោធិសត្វសម្លឹងមើលព្រះចន្ទ្រពេញវង់ដឹងថា ថ្ងៃស្អែកជាថ្ងៃឧបោសថ ទើបពោលនឹងសត្វទាំង ៣ នេះថា ថ្ងៃស្អែកជាថ្ងៃឧបោសថ សូម្បីអ្នកទាំង ៣ ចូរសមាទានសីល រក្សាឧបោសថ ទានដែលអ្នកតាំងនៅក្នុងសីលឲ្យហើយ រមែងមានផលច្រើន ព្រោះហេតុនោះ កាលយាចកមកដល់ហើយ អ្នកទាំងឡាយគប្បីឲ្យរសអាហារដែលគួរបរិភោគហើយទើបបរិភោគចុះ ។ សត្វទាំង ៣ នោះ ទទួលពាក្យហើយនាំគ្នានៅក្នុងទីនៅរបស់ខ្លួនៗ ។ ក្នុងថ្ងៃបន្ទាប់ បណ្ដាសត្វទាំង

នោះ គេគិតថា យើងនឹងស្វែងរកចំណីអំពីព្រឹក ទើប ទៅកាន់ច្រាំងទន្លេគង្គា ។ គ្រានោះ នាយព្រានស្ទូច បានត្រីឆ្ពិន ៧ ទើបយកវល្លិមកដោត ហើយជីកដី ខ្សាច់ត្រង់ច្រាំងទន្លេគង្គា យកខ្សាច់មកគ្រប បិទបាំង ទុក កាលនឹងចាប់ត្រីទៀត ទើបទៅកាន់ផ្នែកខាង ក្រោមទន្លេគង្គា ។ គេហិត បានធុំក្លិនត្រី ទើបកាយ ដីខ្សាច់ បានឃើញត្រីទើបពាំចេញមក ហើយគិតថា ម្ចាស់របស់ត្រីទាំងនេះ មានឬហ្ន៎ ? ទើបប្រកាសឡើង ៣ គ្រា កាលមិនឃើញម្ចាស់របស់ ទើបពាំចុងវល្លិ នាំ ទៅរក្សាទុកក្នុងគុម្ពឈើ ដែលជាទីនៅរបស់ខ្លួន សត្វ គេនោះគិតថា យើងនឹងបរិភោគ កាលដល់វេលា ទើប ដេកនឹកដល់សីលរបស់ខ្លួន ។

ចំណែកឆ្កែចចក កាលត្រាច់ស្វែងរក អាហារ បានឃើញសាច់ ២ ជ្រនួច ទន្សងមួយ និងដបទធិ មួយ ក្នុងខ្ទមរបស់អ្នកចាំស្រែមួយរូប ក៏គិតថា ម្ចាស់

របស់វត្ថុទាំងនេះមានឬមិនមាន ? ទើបស្រែកប្រកាស ៣ គ្រា មិនឃើញម្ចាស់របស់មក ទើបស៊កខ្សែសម្រាប់យួរដេបទធិ ត្រង់ករបស់ខ្លួន យកមាត់ពាំសាច់ និងទន្សង នាំទៅរក្សាទុកក្នុងគុម្ពោតព្រៃ ដែលជាទីនៅរបស់ខ្លួន គិតថានឹងបរិភោគកាលដល់វេលា ទើបដេកនឹកដល់សីលរបស់ខ្លួន ។

ចំណែកឯស្វាវិញ ចូលទៅកាន់ព្រៃសណ្ឋៈ នាំផ្លែស្វាយទុំ មករក្សាទុកក្នុងគុម្ពឈើ ដែលជាទីនៅរបស់ខ្លួន គិតថានឹងបរិភោគកាលដល់វេលា ទើបដេកនឹកដល់សីលរបស់ខ្លួន ។

រីឯព្រះពោធិសត្វ នាកាលដេក ក្នុងទីលំនៅរបស់ខ្លួន បានគិតថា យើងនឹងចេញចាកទីលំនៅ ក្នុងកាលប៉ុណ្ណោះ ហើយបរិភោគស្បូវភ្លាំង ហើយព្រះពោធិសត្វគិតទៀតថា យើងមិនអាចឲ្យស្មៅ ដល់

យាចក អ្នកមកកាន់សំណាក់របស់យើង សូម្បីល្ងនិង អង្ករជាដើម របស់យើងក៏មិនមាន បើយាចកនឹងមក កាន់សំណាក់របស់យើងសោត យើងនឹងឲ្យសាច់ ក្នុង រាងកាយរបស់យើង ។ ដោយតេជៈនៃសីលរបស់ព្រះ ពោធិសត្វនោះ បណ្ឌុកម្ពលសិលាសនៈ របស់សក្កទេវ-រាជ បានសម្ដែងអាការៈក្ដៅ[១] ។ ស្ដេចសក្កៈនោះ កាល ពិចារណាមើល ក៏ឃើញនូវហេតុនោះ ហើយទើបទ្រង់ ត្រិះរិះថា យើងនឹងសាកល្បងស្ដេចទន្សាយ បានមក ហើយកាន់សំណាក់ នៃសត្វភេជាដំបូង បានក្លែងភេទ ជាព្រាហ្មណ៍ ហើយឈរនៅ ។ កាលគេពោលថា ម្នាល ព្រាហ្មណ៍ អ្នកមកដើម្បីត្រូវការអ្វី ? ទើបពោលថា នៃ

---

១. បានឮមកថា បណ្ឌុកម្ពលសិលាសនៈមានអាការៈក្ដៅ ព្រោះ សក្កទេវរាជនឹងអស់អាយុ ឬ អស់បុណ្យ ១ ព្រោះសត្វដទៃដែល មានអានុភាពច្រើនប្រាថ្នាស្ថានទីនោះ ១ ព្រោះតេជៈ នៃសីល របស់សមណព្រាហ្មណ៍ដែលតាំងនៅក្នុងធម៌ ១ ។

ភោបណ្ឌិត ខ្ញុំគប្បីបានអាហារខ្លះ នឹងជាអ្នករក្សាឧបោសថ ធ្វើសមណធម៌ ។ ភេនោះពោលថា សាធុ ល្អហើយ ខ្ញុំនឹងឲ្យអាហារ ដល់លោក កាលចរចាជាមួយព្រាហ្មណ៍នោះ បានពោលគាថាទី ១ ថា

**សត្ត មេ រោហិតា មច្ឆា, ឧទកា ថលមុព្ភតា**
**ឥទំ ព្រាហ្មណ មេ អត្ថិ, ឯតំ ភុត្វា វនេ វស ។**

ខ្ញុំមានត្រីឆ្ពិន ៧ ដែលព្រានស្ទូចស្រង់ឡើង ពីទឹកដាក់លើគោក ម្នាលព្រាហ្មណ៍ នេះរបស់ខ្ញុំ អ្នកចូរបរិភោគរបស់នេះ ហើយ (ចម្រើនសមណធម៌) នៅក្នុងព្រៃចុះ ។

ពាក្យថា **អ្នកចូរបរិភោគរបស់នេះ** សេចក្ដីថា លោកចូរចម្អិនមច្ឆាហារ ដែលជារបស់ខ្ញុំនោះ ហើយបរិភោគចុះ កាលធ្វើសមណធម៌ ចូរអង្គុយត្រង់គល់ឈើ ដែលជាទីគួរត្រេកអរ ក្នុងព្រៃនេះចុះ ។

ព្រាហ្មណ៍ពោលថា រឿងនេះ ចូរលើកទុកសិន ចុះ ខ្ញុំនឹងដឹងក្នុងកាលជាខាងក្រោយ ហើយទៅកាន់សំណាក់ឆ្កែចចក សូម្បីឆ្កែចចកចេញមក ពោលថា លោកមកឈរ (ត្រង់នេះ) ដើម្បីត្រូវការអ្វី ? ព្រាហ្មណ៍ពោលយ៉ាងនោះដូចគ្នា ។ ឆ្កែចចកពោលថា សាធុ ល្អហើយ ខ្ញុំនឹងឲ្យ កាលចរចានឹងព្រាហ្មណ៍នោះ បានពោលគាថាទី ២ ថា

**ទុស្ស មេ ខេត្តបាលស្ស, រត្តិភត្តំ អបាភតំ**
**មំសសូលា ច ទ្វេ គោធា, ឯកញ្ច ទធិវារកំ**
**ឥទំ ព្រាហ្មណ មេ អត្ថិ, ឯតំ ភុត្វា វនេ វស។**

ភត្ត របស់អ្នករក្សាស្រែឯណោះ គឺសាច់ពីរជ្រនួចផង ទន្សងមួយផង ដបទធិមួយផង ខ្ញុំបាននាំមកក្នុងវេលាយប់ ម្នាលព្រាហ្មណ៍ នេះរបស់ខ្ញុំ អ្នកចូរ

បរិភោគរបស់នេះ ហើយ (ចម្រើនសមណធម៌) នៅក្នុងព្រៃចុះ ។

ពាក្យថា **សាច់ពីរជ្រនួចផង ទន្សងមួយផង** សេចក្ដីថា សាច់អាំង ២ ជ្រនួចដែលនៅលើរងើកភ្លើង និងទន្សង ១ ក្បាល ។ ពាក្យថា **ដបទធិមួយផង** បានដល់ ដបទឹកដោះជូរ ។ ពាក្យថា **របស់នេះ** ជាដើមទៅ មានសេចក្ដីថា យើងមានវត្ថុនេះ គឺមានប្រមាណប៉ុណ្ណេះ លោកចូរចម្អិនវត្ថុនេះ សូម្បីទាំងអស់ ដោយការធ្វើឲ្យឆ្អិនតាមសេចក្ដីពេញចិត្ត ហើយបរិភោគ និងជាអ្នកសមាទានឧបោសថ អង្គុយត្រង់គល់ឈើ ដែលជាទីមនោរម្យ ធ្វើសមណធម៌នៅក្នុងព្រៃនេះចុះ ។

ព្រាហ្មណ៍ពោលថា រឿងនេះ ចូរលើកទុកសិនចុះ ខ្ញុំនឹងដឹងក្នុងកាលជាខាងក្រោយ ហើយទៅកាន់សំណាក់របស់ស្វា សូម្បីស្វានោះពោលថា លោកមក

ឈរ (ត្រង់នេះ) ដើម្បីត្រូវការអ្វី ? ព្រាហ្មណ៍ក៏ពោលយ៉ាងនោះដូចគ្នា ។ ស្វាពោលថា សាធុ ល្អហើយ ខ្ញុំនឹងឲ្យ កាលចរចានឹងព្រាហ្មណ៍នោះ បានពោលគាថាទី ៣ ថា

**អម្ពបក្កំ ទកំ សីតំ, សីតច្ឆាយា មនោរមា**
**ឥធំ ព្រាហ្មណ មេ អត្ថិ, ឯតំ ភុត្វា វនេ វសា។**

***ផ្លែស្វាយទុំ ទឹកត្រជាក់ ទីមានម្លប់ត្រជាក់ ជាទីគាប់ចិត្ត ម្នាលព្រាហ្មណ៍ នេះជារបស់ខ្ញុំ អ្នកចូរបរិភោគរបស់នេះ ហើយ (ចម្រើនសមណធម៌) នៅក្នុងព្រៃចុះ ។***

*ពាក្យថា **ផ្លែស្វាយទុំ** បានដល់ ផ្លែស្វាយទុំដ៏ឆ្ងាញ់ ។ បទថា **ទឹកត្រជាក់** បានដល់ ទឹកនៃទន្លេគង្គាដ៏ត្រជាក់ ។ បទថា **ចូរបរិភោគរបស់នេះ** សេចក្ដីថា ម្នាលព្រាហ្មណ៍ លោកចូរបរិភោគផ្លែស្វាយនេះ និងផឹកទឹក*

ត្រជាក់នេះ អង្គុយត្រង់គល់ឈើ ដែលជាទីករាយ ហើយ ធ្វើសមណធម៌នៅក្នុងព្រៃនេះចុះ ។

ព្រាហ្មណ៍ពោលថា រឿងនេះ ចូរលើកទុកសិនចុះ ខ្ញុំនឹងដឹងក្នុងកាលជាខាងក្រោយ ហើយទៅកាន់សំណាក់សសបណ្ឌិត សូម្បីសសបណ្ឌិតនោះពោលថា លោកមកឈរ (ត្រង់នេះ) ដើម្បីត្រូវការអ្វី ? ព្រាហ្មណ៍ក៏ពោលយ៉ាងនោះដូចគ្នា ។ ព្រះពោធិសត្វបានស្តាប់ដូចនោះ ក៏មានសេចក្តីរីករាយ សោមនស្សពោលថា ម្នាលព្រាហ្មណ៍ លោកមកកាន់សំណាក់របស់យើងដើម្បីត្រូវការអាហារ ជាការល្អហើយ ថ្ងៃនេះ យើងនឹងឲ្យទាន ដែលយើងមិនធ្លាប់ឲ្យ លោកជាអ្នកមានសីល មិនធ្វើបាណាតិបាត លោកចូរទៅប្រមូលឈើផ្សេងៗ មកបង្កជាភ្លើង ហើយចូរប្រាប់ដល់យើង យើងនឹងលះខ្លួន លោតចុះក្នុងរងើកភ្លើង កាលរាងកាយរបស់យើងឆ្អិនហើយ លោកចូរបរិភោគសាច់

ហើយ ធ្វើសមណធម៌ កាលចរចានឹងព្រាហ្មណ៍នោះ ទើបពោលគាថាទី ៤ ថា

**ន សសស្ស តិលា អត្ថិ, ន មុគ្គា នបិ តណ្ឌុលា**
**ឥមិនា អគ្គិនា បក្កំ, មមំ ភុត្វា វនេ វសា។**

**ទន្សាយមិនមានល្ង មិនមានសណ្ដែក មិនមាន អង្ករទេ អ្នកចូរបរិភោគនូវខ្ញុំ ដែលឆ្អិនដោយភ្លើងនេះ ហើយ (ចម្រើនសមណធម៌) នៅក្នុងព្រៃចុះ ។**

ពាក្យថា **ចូរបរិភោគនូវខ្ញុំ** សេចក្ដីថា លោកចូរបរិភោគយើង ដែលឆ្អិនដោយភ្លើង ដែលយើងប្រាប់ឲ្យលោកបង្កទ្បើងនេះ ហើយចូរនៅ ក្នុងព្រៃនេះ ធម្មតាថា រាងកាយរបស់ទន្សាយមួយ រមែងញ៉ាំងជីវិតរបស់បុរសម្នាក់ ឲ្យប្រព្រឹត្តទៅបាន ។

ស្ដេចសក្កៈបានស្ដាប់ពាក្យ របស់សសបណ្ឌិតនោះហើយ ទើបនិម្មិតគំនរភ្លើងមួយ ដោយអានុភាព

របស់ខ្លួន ហើយប្រាប់ព្រះពោធិសត្វ ។ ព្រះពោធិសត្វ នោះក្រោកឡើងអំពីទីនៅ ដែលជាស្បូវក្ដាំង របស់ខ្លួន ហើយ ទៅកាន់គំនររងើកភ្លើងនោះ គិតថា បើសត្វ តូចៗ ក្នុងរវាងរោមរបស់យើងមាន សត្វទាំងនោះ ចូរកុំស្លាប់ឡើយ ហើយរលាស់ខ្លួន ៣ ដង បានញុំាងសរីរៈទាំងអស់ ឲ្យតម្កល់ទុកក្នុងប្រធាននៃទាន លោតចុះលើគំនររងើកភ្លើង ដោយចិត្តរីករាយ បីដូចជារាជហង្សដែលលោតចុះក្នុងស្រះឈូក ។ តែភ្លើងនោះមិនអាចធ្វើសេចក្ដីក្ដៅ សូម្បីប៉ុនរណ្ដៅរោម ក្នុងរាងកាយរបស់ព្រះពោធិសត្វ ហាក់បីដូចជា ចូលទៅក្នុងបន្ទប់ទឹកកកដូច្នោះ ។ លំដាប់នោះ ព្រះពោធិសត្វហៅសក្កទេវរាជមកពោលថា ម្នាលព្រាហ្មណ៍ ភ្លើងដែលលោកបង្កើតឡើងនេះ ត្រជាក់ណាស់ មិនអាចធ្វើសេចក្ដីក្ដៅ សូម្បីប៉ុនរណ្ដៅរោម ក្នុងរាងកាយរបស់ខ្ញុំ ឡើយ អ្នកឈ្មោះអ្វី ? ស្ដេចសក្កៈពោលថា ម្នាល ស សបណ្ឌិត យើងមិនមែនជា ព្រាហ្មណ៍ទេ យើងជាសក្ក

ទេវរាជ មកដើម្បីនឹងសាកល្បងលោក ។ ព្រះពោធិសត្វបន្លឺសីហនាទថា បពិត្រសក្កៈ ព្រះអង្គចូរឈប់សិន បើលោកសន្និវាសទាំងអស់ គប្បីសាកល្បងនឹងខ្ញុំដោយទាន នឹងមិនគប្បីឃើញភាព ជាអ្នកប្រាថ្នាក្នុងការមិនឲ្យរបស់ខ្ញុំព្រះអង្គឡើយ ។ លំដាប់នោះស្ដេចសក្កៈទើបត្រាស់នឹងព្រះពោធិសត្វនោះថា ម្នាលសសបណ្ឌិត គុណរបស់លោក ចូរប្រាកដ រហូតកប្បទាំងអស់ចុះ ហើយទ្រង់ច្របាច់ភ្នំ បានកាន់យកជ័រនៃភ្នំ ហើយគូសនូវលក្ខណៈរបស់ទន្សាយ (គូររូបទន្សាយ) លើមណ្ឌលនៃព្រះចន្ទ្រ ហើយនាំព្រះពោធិសត្វ មកឲ្យដេកលើដំបូលស្បូវភ្លាំងជំទន់ ក្នុងគុម្ពឈើ ក្នុងព្រៃសណ្ឌៈនោះឯង ហើយទ្រង់ទៅហើយកាន់ទីលំនៅរបស់ខ្លួន ។ សូម្បីបណ្ឌិតទាំង ៤ នោះព្រមព្រៀងគ្នា កាលត្រេកអររីករាយ បានបំពេញនូវសីល បានឲ្យទាន ធ្វើឧបោសថកម្ម បានទៅហើយតាមយថាកម្ម (រៀងៗខ្លួន) ។

ព្រះសាស្តា បាននាំព្រះធម្មទេសនានេះ មកហើយ ទើបទ្រង់ប្រកាសសច្ចៈ ប្រជុំជាតក ក្នុងទីបំផុតនៃការប្រកាសសច្ចៈ គហបតីអ្នកថ្វាយបរិក្ខារ គ្រប់យ៉ាង បានតាំងនៅក្នុងសោតាបត្តិផល ។

ភេក្នុងកាលនោះ បានមកជាអានន្ទ

ឆ្កែចកកបានមកជាមោគ្គល្លាន

ស្វាបានមកជាសារីបុត្រ

សក្កទេវរាជបាន មកជាអនុរុទ្ធ

ចំណែកសសបណ្ឌិត គឺតថាគត នេះឯង ។

ចប់សសបណ្ឌិតជាតក ។

(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ចតុក្កនិបាត បុចិមន្ទវគ្គ បិដកលេខ ៥៨ ទំព័រ ២០២)

# ២. វដ្តកជាតក

## (ភ្លើងមិនឆេះក្នុងវដ្តកជាតក)

*ព្រះបរមសាស្តា កាលស្តេចត្រាច់ចារិកក្នុងដែនមគធៈ ទ្រង់ប្រារព្ធការរលត់នៃភ្លើងឆេះព្រៃ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **សន្តិ បក្ខា អបតនា** *ដូច្នេះជាដើម ។*

*សម័យមួយ ព្រះបរមសាស្តា កាលស្តេចត្រាច់ចារិកទៅក្នុងដែនមគធៈ ទ្រង់ត្រាច់បិណ្ឌបាតក្នុងស្រុកមគធៈមួយកន្លែង ហើយត្រឡប់អំពីបិណ្ឌបាត ខាងក្រោយភត្ត កាលពួកភិក្ខុចោមរោមហើយ ទ្រង់ព្រះដំណើរយាងទៅកាន់ផ្លូវ ។ ក្នុងពេលនោះ ភ្លើងព្រៃដ៏ធំក៏តាំងឡើង ភិក្ខុជាច្រើនឃើញទាំងខាងមុខនិងខាងក្រោយ, ភ្លើងនោះមានផ្សែងសន្ធោសន្ធៅ មានអណ្តាតភ្លើងដ៏ក្រាស់កំពុងឆេះរាលមក ។ បណ្តាភិក្ខុទាំងនោះ*

ភិក្ខុបុថុជ្ជនពួកមួយ ខ្លាចចំពោះមរណភ័យពោលថា ពួកយើងនឹងដុតភ្លើងកាត់ ភ្លើងដែលឆេះមកនឹងមិនឆេះពួកយើងឡើយ ទើបនាំវត្ថុដែលប្រព្រឹត្តទៅមួយអន្លើដោយពំនួតភ្លើងមកបង្កាត់ភ្លើង ។ ចំណែកភិក្ខុខ្លះទៀតពោលថា នែអាវុសោ ពួកអ្នកធ្វើកម្មអ្វី ពួកអ្នកមិនឃើញព្រះសម្មាសម្ពុទ្ធ ដែលជាអគ្គបុគ្គល ក្នុងលោកព្រមទាំងទេវលោក ទ្រង់យាងមកជាមួយខ្លួនទេឬ ពួកអ្នកហាក់ដូចជា បុគ្គលមិនឃើញមណ្ឌលព្រះចន្ទ្រដែលឋិតនៅលើមេឃ ដូចជាមិនឃើញមណ្ឌលព្រះអាទិត្យ ដែលបញ្ចេញរស្មីរាប់ពាន់ រះឡើងអំពីលោកធាតុទិសខាងកើត ដូចបុគ្គលឈរត្រង់ច្រាំងសមុទ្ទ មិនឃើញសមុទ្ទ និងដូចបុគ្គលឈរផ្អែកភ្នំសិនេរុ មិនឃើញភ្នំសិនេរុដូច្នោះ នាំគ្នាពោលថា ដុតភ្លើងដើម្បីកាត់មុខភ្លើង ឈ្មោះថា កម្លាំងរបស់ព្រះពុទ្ធ ពួកអ្នកមិនដឹងទេឬ អ្នកទាំងឡាយចូរមក ពួកយើងនឹងទៅ

កាន់សម្នាក់របស់ព្រះសាស្តា ។ ភិក្ខុទាំងនោះ កាលទៅខាងមុខ និងខាងក្រោយជុំវិញ បានរួមគ្នាក្នុងសម្នាក់របស់ព្រះទសពល ។ ព្រះសាស្តាមានភិក្ខុជាច្រើនជាបរិវារ ទ្រង់ប្រថាប់ឈរលើកន្ទេងមួយ ។ ភ្លើងព្រៃដែលមានសម្ទេងខ្លាំង ឆេះរាលមក ហាក់ដូចជានឹងញាំញីកាលមកដល់ ជិតទីដែលព្រះតថាគត ប្រថាប់ឈរប្រមាណ ១៦ ករីសៈ ដោយជុំវិញ ក៏រលត់ទៅ ដូចគប់ភ្លើងស្មៅដែលលិចចុះទៅក្នុងទឹកដូច្នោះ មិនអាចគ្របសង្កត់ក្នុងទីប្រមាណ ៣២ ករីសៈ ដោយការរោលចូលមក ។

ភិក្ខុទាំងឡាយនាំគ្នា ពោលប្រារព្ធគុណ របស់ព្រះសាស្តាថា ឈ្មោះថា គុណព្រះពុទ្ធទាំងឡាយអស្ចារ្យណាស់ ភ្លើងសូម្បីមិនមានចិត្ត ក៏មិនអាចគ្របសង្កត់ទីដែលព្រះពុទ្ធប្រថាប់ឈរ រមែងរលត់ទៅ ដូចគប់ភ្លើងស្មៅធ្លាក់ចុះដល់ទឹក រលត់ទៅដូច្នោះ ឈ្មោះ

ថា អានុភាពរបស់ព្រះពុទ្ធទាំងឡាយ គួរអស្ចារ្យណាស់ ។

ព្រះសាស្តាស្តាប់ពាក្យរបស់ភិក្ខុទាំងនោះហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលដែលភ្លើង (ឆេះមក) ដល់កន្លែងនេះហើយរលត់ទៅ ជាកម្លាំងរបស់តថាគត ក្នុងកាលឥឡូវនេះក៏មិនមែន សេចក្តីនេះ ជាកម្លាំងនៃសច្ចៈ ដែលមានក្នុងកាលមុន របស់តថាគត ដ្បិតថា ត្រង់កន្លែងនេះ ភ្លើងមិនឆេះអស់មួយកប្ប នេះឈ្មោះថា **កប្បដ្ឋិយបាដិហារ្យ** (បាដិហារ្យដែលតាំងនៅអស់កប្ប) ។ លំដាប់នោះ ព្រះអានន្ទក្រាលសង្ឃាដីបួនជាន់ ដើម្បីជាទីគង់ប្រថាប់របស់ព្រះមានព្រះភាគ ។ ព្រះបរមសាស្តា ទ្រង់គង់ពត់ព្រះភ្នែន ។ ចំណែកភិក្ខុសង្ឃក៏ថ្វាយបង្គំព្រះតថាគត ហើយអង្គុយចោមរោម ។ លំដាប់នោះ ព្រះមានព្រះភាគ កាលភិក្ខុទាំងឡាយក្រាបទូលអារាធនាថា បពិត្រ

ព្រះអង្គដ៏ចម្រើន រឿងនេះ ប្រាកដខ្ញុំព្រះអង្គទាំងឡាយហើយ ចំណែករឿងក្នុងអតីតជាអាថ៌កំបាំងនៅឡើយ សូមទ្រង់ត្រាស់សម្ដែងរឿងក្នុងអតីត ដែលជាអាថ៌កំបាំងនោះផងចុះ ទើបព្រះសាស្ដាទ្រង់នាំយកអតីតនិទានមកសម្ដែងដូចតទៅថា

ក្នុងអតីតកាល ក្នុងដែនមគធៈ ត្រង់ប្រទេសនេះឯង ព្រះពោធិសត្វបដិសន្ធិក្នុងកំណើតសត្វក្រួចកើតអំពីឧទរមាតា ក្នុងវេលាទម្លាយសម្បកស៊ុតចេញមក បានជាកូនក្រួចមានខ្លួនប្រមាណប៉ុនកូនឃ្លីអាធំ ។ លំដាប់នោះ មេបាឲ្យព្រះពោធិសត្វដេក ក្នុងសម្បុកហើយនាំអាហារមកចិញ្ចឹមដោយចំពុះ ។ ព្រះមហាសត្វនោះ មិនមានកម្លាំងដែលអាចបើកស្លាបហើរទៅក្នុងអាកាស និងមិនមានកម្លាំងអាចលើកជើង ដើរទៅឡើយ ។ សម័យនោះ ភ្លើងព្រៃតែងឆេះប្រទេសនោះរាល់ៗឆ្នាំ ភ្លើងព្រៃនោះមានសម្លេងលាន់កងរំពង ឆេះ

ត្រង់កន្លែងនោះ ពួកបក្សីទាំងឡាយនាំគ្នាហើរចោល សម្បុករៀងៗខ្លួន ខ្លាចចំពោះមរណភ័យ ស្រែកខ្សៀវខ្សារ ហើរគេចទៅ មេបារបស់ព្រះពោធិសត្វក៏ខ្លាចចំពោះមរណភ័យ បោះបង់ព្រះពោធិសត្វ ហើយគេចទៅដែរ ។ ព្រះពោធិសត្វដេកក្នុងសម្បុកនោះ អើតកឡើង ឃើញភ្លើងព្រៃកំពុងឆេះរាលមក ទើបគិតថា បើអញមានកម្លាំងអាចលើកស្លាបហើរទៅក្នុងអាកាសបានសោត អញគប្បីហើរទៅកាន់ទីដទៃ បើអញមានកម្លាំងអាចលើកជើងដើរទៅបានសោត អញនឹងលើកជើងដើរទៅកាន់ទីដទៃ ចំណែកមេបា របស់អញក៏ខ្លាចចំពោះសេចក្ដីស្លាប់ បោះបង់អាត្មាអញចោលតែម្នាក់ឯង កាលនឹងការពារខ្លួន ទើបគេចទៅ ឥឡូវនេះទីពឹងដទៃរបស់អាត្មាអញមិនមានឡើយ អញមិនមានទីពឹង ថ្ងៃនេះ អញគួរនឹងធ្វើដូចម្ដេច ។

លំដាប់នោះ ព្រះពោធិសត្វមានគំនិតយ៉ាងនេះ ថា ឈ្មោះថា គុណនៃសីល រមែងមានក្នុងលោក, ឈ្មោះថា គុណនៃសច្ចៈក៏រមែងមាន, ក្នុងអតីតកាល ឈ្មោះថា ព្រះសព្វញ្ញុពុទ្ធ ដែលបំពេញបារមី ទាំងឡាយហើយ ទ្រង់គង់ត្រង់មណ្ឌលពោធិព្រឹក្ស បានត្រាស់ដឹងអភិសម្ពោធិញាណហើយ ទ្រង់ដល់ ព្រមដោយសីល សមាធិ បញ្ញា វិមុត្តិ និងវិមុត្តិញាណ-ទស្សនៈ ទ្រង់ប្រកបដោយសច្ចៈ មេត្តា ករុណា ខន្តី ទ្រង់មានមេត្តាប្រព្រឹត្តទៅព្រមក្នុងសត្វទាំងពួង រមែង មាន, ឯគុណរបស់ព្រះធម៌ ដែលព្រះសព្វញ្ញុពុទ្ធ ទាំងឡាយនោះ ទ្រង់ដឹងច្បាស់ហើយ ក៏រមែងមាន បើ សច្ចៈឯណានីមួយ រមែងមាននៅក្នុងអញពិត សភាវ-ធម៌ឯណានីមួយ ក៏រមែងមានប្រាកដ ព្រោះហេតុនោះ អញរឭកដល់អតីតពុទ្ធទាំងឡាយ និងគុណដែលព្រះ ពុទ្ធក្នុងអតីតទាំងនោះចាក់ធ្លុះហើយ កាន់យកសភាវ-

ធម៌គឺសច្ចៈ ដែលមាននៅក្នុងខ្លួនអាត្មាអញ ធ្វើនូវសច្ច-កិរិយា ឲ្យភ្លើងថយត្រឡប់ គួរនឹងធ្វើសួស្តីដល់ខ្លួន និងពួកបក្សីដ៏សេស ក្នុងថ្ងៃនេះចុះ ដោយហេតុនោះ ទើបពោលថា

**អត្ថិ លោកេ សីលគុណោ, សច្ចំ សោចេយ្យនុទ្ទយា;**
**តេន សច្ចេន កាហាមិ, សច្ចកិរិយមនុត្តរំ។**

ព្រះសព្វញ្ញុពុទ្ធ ប្រកបដោយសីលគុណ សច្ចៈ សោចេយ្យ (សេចក្តីស្អាត) និងសេចក្តីអាណិត សឹងមានក្នុងលោក (បើដូច្នោះ) អញនឹងធ្វើនូវសច្ចកិរិយាដ៏ឧត្តម ដោយសច្ចៈនោះ ។

**អាវជ្ជេត្វា ធម្មពលំ, សរិត្វា បុព្ពកេ ជិនេ;**
**សច្ចពលមវស្សាយ, សច្ចកិរិយមកាសហំ។**

តថាគតពិចារណាកម្លាំងធម៌ ហើយរឭកព្រះជិនស្រីក្នុងកាលមុន ធ្វើសច្ចកិរិយា ព្រោះអាស្រ័យកម្លាំងសច្ចធម៌ (នោះ) ។ (ខុទ្ទកនិកាយ ចរិយាបិដក)

លំដាប់នោះ ព្រះពោធិសត្វរឭកដល់ព្រះគុណរបស់ព្រះពុទ្ធទាំងឡាយ ដែលបរិនិព្វានទៅហើយ ក្នុងអតីត ហើយប្រារព្ធដល់សភាវសច្ចៈ ដែលមាននៅក្នុងខ្លួន កាលធ្វើសច្ចកិរិយា ទើបពោលគាថានេះថា

**សន្តិ បក្ខា អបតនា, សន្តិ បាទា អវញ្ចនា;**
**មាតាបិតា ច និក្ខន្តា, ជាតវេទ បដិក្កម។**

**ស្លាបទាំងឡាយមាន តែហើរមិនរួច ជើងទាំងឡាយមាន តែដើរមិនបាន មេនិងបា (របស់យើង) ចេញបាត់ទៅហើយ នៃភ្លើងព្រៃ អ្នកចូរថយទៅចុះ ។**

ពាក្យថា **ស្លាបទាំងឡាយមាន តែហើរមិនរួច** សេចក្តីថា ឈ្មោះថា ស្លាបទាំងពីររបស់ខ្ញុំមាន គឺកើត

មាន តែមិនអាចហើរ គឺមិនអាចទៅតាមអាកាសដោយ ស្លាបនោះបាន ព្រោះហេតុនោះ ទើបឈ្មោះថា ហើរមិនបាន ។

ពាក្យថា **ជើងទាំងឡាយមាន តែដើរមិនបាន** សេចក្តីថា សូម្បីជើងទាំងពីររបស់ខ្ញុំ ក៏មាន តែមិនអាចដើរបាន គឺទៅដោយអាការដែលឈានទៅដោយជើងទាំងពីរនោះមិនបាន ព្រោះហេតុនោះ ទើបឈ្មោះថា ដើរមិនបាន ។

ពាក្យថា **មេនិងបា (របស់យើង) ចេញបាត់ទៅហើយ** សេចក្តីថា ម្យ៉ាងទៀត សូម្បីមាតាបិតា ដែលនឹងនាំខ្ញុំទៅកាន់ទីដទៃនោះ ក៏ហើរទៅហើយ ព្រោះខ្លាចសេចក្តីស្លាប់ ។

ព្រះមហាសត្វដេកក្នុងសម្បុកនោះឯង បានធ្វើសច្ចកិរិយាថា បើស្លាបទាំងពីររបស់ខ្ញុំមាន គឺការបើកស្លាបទាំងពីរ ហើរទៅក្នុងអាកាសមិនបាន ១ ភាពនៃជើងមាន តែជើងនោះដើរមិនបាន ១ ភាពដែលមាតាបិតាបោះបង់ខ្ញុំទុកក្នុងសម្បុកនោះ ហើយហើរទៅ ១ ទាំងអស់នេះជាសភាវសច្ចៈ ម្នាលភ្លើងព្រៃ ដោយពាក្យសច្ចៈនេះ ចូរអ្នកត្រឡប់អំពីទីនេះ ។ ដំណាលគ្នានឹងសច្ចកិរិយា របស់ព្រះពោធិសត្វ ភ្លើងបានថយត្រឡប់ទៅក្នុងទីប្រមាណ ១៦ ករីសៈ ឯការថយត្រឡប់ទៅ ក៏ឆេះក្នុងទីដទៃក្នុងព្រៃ ទាំងរលត់ហើយក្នុងទីនោះឯង ដូចគប់ភ្លើងដែលបុគ្គលជ្រលក់ក្នុងទឹកដូច្នោះ ដោយហេតុនោះ ទើបលោកពោលថា

**សហ សច្ចេ កតេ មយ្ហំ, មហាបជ្ជលិតោ សិខី;**
**វជ្ជេសិ សោឡស ករីសានិ, ឧទកំ បត្វា យថា សិខី។**

ព្រោះសច្ចកិរិយា ដែលតថាគតបានធ្វើហើយ ភ្លើងដែលឆេះសន្ធោសន្ធៅ ក៏ចៀសចម្ងាយ ១៦ ករីសៈ

(ហើយរលត់ក្នុងទីនោះ) ដូចជា គប់ភ្លើងដែលបុគ្គលជ្រលក់ទៅក្នុងទឹក ។

ឯស្ថានទីនេះ កើតប្រាកដជា បាដិហារិយ៍ឈ្មោះ **កប្បដ្ឋិយបាដិហារ្យ** (បាដិហារ្យតាំងនៅអស់មួយកប្ប) ព្រោះភ្លើងមិនឆេះ ក្នុងទីនេះទាំងមូល ។ ព្រះពោធិសត្វ កាលធ្វើសច្ចកិរិយាយ៉ាងនេះហើយ ក្នុងវេលាអស់ជីវិត ក៏ទៅតាមយថាកម្ម ។

ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការដែលភ្លើង មិនឆេះក្នុងទីនេះ ជាកម្លាំងរបស់**តថាគត**ក្នុងកាលឥឡូវនេះ ក៏មិនមែន តែនោះជាកម្លាំងសច្ចៈរបស់តថាគត កាលតថាគតកើតជាសត្វក្រួច ក្នុងទីនេះ ។

ព្រះបរមសាស្ដា បាននាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងវេលា

ចប់សច្ចៈ ភិក្ខុពួកខ្លះបានជាព្រះសោតាបន្ន ភិក្ខុពួកខ្លះបានជាព្រះសកទាគាមី ភិក្ខុខ្លះបានសម្រេចជាព្រះអនាគាមី ភិក្ខុខ្លះក៏សម្រេចព្រះអរហត្ត ។ ព្រះសាស្តាទ្រង់បន្តអនុសន្ធិប្រជុំជាតកថា មេបាក្នុងកាលនោះបានមកជាមាតាបិតា ក្នុងកាលឥឡូវនេះ ចំណែកស្តេចក្រួច គឺ តថាគត នេះឯង ៕

(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ឯកកនិបាត កុលាវកវគ្គ )

# ៣. ឃដិការសូត្រ

## (ភ្ញៀវមិនស្រក់ចុះក្នុងផ្ទះឃដិការស្ទួនឆ្នាំង)

*ខ្ញុំបានស្តាប់ចាំមកយ៉ាងនេះ។ សម័យមួយព្រះមានព្រះភាគទ្រង់ស្តេចទៅកាន់ចារិកក្នុងដែនកោសលព្រមដោយភិក្ខុសង្ឃច្រើនអង្គ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ងាក (ព្រះភក្ត្រ) បែរចេញអំពីផ្លូវហើយបានធ្វើនូវការញញឹម ត្រង់ទៅរកប្រទេសមួយ ឲ្យប្រាកដ។ វេលានោះ ព្រះអានន្ទមានអាយុមានសេចក្តីត្រិះរិះដូច្នេះថា មានហេតុដូចម្តេចហ្ន៎ មានបច្ច័យដូចម្តេចហ្ន៎ ជាហេតុនាំឲ្យព្រះមានព្រះភាគ ធ្វើនូវការញញឹមឲ្យប្រាកដឡើង (ព្រោះថា) ព្រះតថាគតទាំងឡាយមិនដែលធ្វើនូវការញញឹម ឲ្យប្រាកដ ដោយឥតហេតុទេ។*

*លំដាប់នោះ ព្រះអានន្ទមានអាយុធ្វើ នូវឧត្តរាសង្គៈឆៀងស្មាម្ខាង ប្រណម្យអញ្ជលីចំពោះព្រះមានព្រះភាគហើយក្រាបបង្គំទូលសួរ ចំពោះព្រះមានព្រះ*

ភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន មានហេតុដូចម្តេចហ្ន៎ មានបច្ច័យដូចម្តេចហ្ន៎ ជាហេតុនាំឲ្យព្រះមានព្រះភាគធ្វើនូវការញញឹម ឲ្យប្រាកដឡើង (ព្រោះថា) ព្រះតថាគតទាំងឡាយ មិនដែលធ្វើនូវការញញឹម ឲ្យប្រាកដដោយឥតហេតុទេ។

ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ រឿងរ៉ាវធ្លាប់មានមកហើយក្នុងប្រទេសនេះ មាននិគមមួយឈ្មោះវេភឡិគៈ ជានិគមស្តុកស្តម្ភ មាំមួន មានជនច្រើន មានមនុស្សកុះករ។ ម្នាលអានន្ទ ព្រះកស្សបមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ធ្លាប់ចូលមក សម្រេចសម្រាន្តឥរិយាបថ ក្នុងវេភឡិគនិគមនោះឯង។ ម្នាលអានន្ទ អារាម របស់ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធមាននៅក្នុងទីនេះ។ ម្នាលអានន្ទ ព្រះកស្សបមានព្រះភាគអរហន្តសម្មាសម្មាសម្ពុទ្ធ តែងគង់ឲ្យឱវាទភិក្ខុសង្ឃក្នុងទីនេះ។

គ្រានោះឯង ព្រះអានន្ទមានអាយុ ក្រាលសង្ឃាដិមានជាន់ ៤ ហើយ ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន បើដូច្នោះ សូមព្រះមានព្រះភាគ ទ្រង់គង់សិន កាលបើព្រះអង្គគង់ហើយភូមិប្រទេសនេះ នឹងបានឈ្មោះថា មានព្រះអរហន្តសម្មាសម្ពុទ្ធពីរព្រះអង្គប្រើប្រាស់។ ព្រះមានព្រះភាគក៏ទ្រង់គង់លើអាសនៈ ដែលព្រះអានន្ទក្រាលថ្វាយ។ លុះព្រះមានព្រះភាគគង់ស៊ប់ហើយ ក៏ត្រាស់ទៅនឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ រឿងរ៉ាវធ្លាប់មានមកហើយ ក្នុងប្រទេសនេះ មាននិគមមួយឈ្មោះវេកឡិគៈជានិគមស្តុកស្តម្ភមាំមួន មានជនច្រើនមានមនុស្សកុះករ។ ម្នាលអានន្ទ ព្រះកស្សបមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ធ្លាប់ចូលមកសម្រេចសម្រាន្តឥរិយាបថ ក្នុងវេកឡិគនិគមនេះឯង។ ម្នាលអានន្ទអារាម របស់ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធមាននៅក្នុងទីនេះឯង។ ម្នាលអានន្ទ ព្រះ

កស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ តែងគង់ឲ្យឱវាទភិក្ខុសង្ឃក្នុងទីនេះ។ ម្នាលអានន្ទ ក្នុងវេភឡិគនិគមមានស្មូនឆ្នាំងម្នាក់ឈ្មោះ **ឃដិការ** ជាឧបដ្ឋាកជាអ្នកបម្រើដ៏ប្រសើរ របស់ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ។ ម្នាលអានន្ទ ស្មូនឆ្នាំងឈ្មោះឃដិការនោះឯង មានមាណពម្នាក់ឈ្មោះ **ជោតិបាល** ជាមិត្តសម្លាញ់ពេញចិត្ត (របស់គាត់) ។ ម្នាលអានន្ទ គ្រានោះ ឃដិការស្មូនឆ្នាំង និយាយនឹងជោតិបាលមាណពថា នែជោតិបាលសម្លាញ់ស្មោះស្មើចិត្ត មកយើងនឹងនាំគ្នា ទៅគាល់ព្រះកស្សបមានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធ ព្រោះថាការបានឃើញ នូវព្រះមានព្រះភាគជា អរហន្តសម្មាសម្ពុទ្ធអង្គនោះ របស់ខ្ញុំសន្មតថា ជាការប្រពៃ។

ម្នាលអានន្ទ កាលដែលឃដិការស្មូនឆ្នាំងនិយាយយ៉ាងនេះ ជោតិបាលមាណពក៏ឃាត់ឃដិការស្មូនឆ្នាំងដូច្នេះថា កុំឡើយ ឃដិការសម្លាញ់ស្មោះស្មើ

ចិត្ត ចុះអ្នកឯងចង់គាល់ស្រមណ៍កំណោរនោះបានជាការអ្វី។ ម្នាលអានន្ទ ឃដិការស្មូនឆ្នាំងនិយាយអស់វារៈ ២ដង ។បេ។ ម្នាលអានន្ទ ឃដិការស្មូនឆ្នាំងនិយាយនឹងជោតិបាលមាណពអស់វារៈ៣ដងដូច្នេះថា នៃជោតិ-បាលសម្លាញ់ស្មោះស្មើចិត្ត មក យើងនឹងនាំគ្នាចូលទៅគាល់ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រោះថា ការបានឃើញព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ របស់ខ្ញុំសន្មតថា ជាការប្រពៃ។ ម្នាលអានន្ទ ជោតិបាលមាណព ក៏ឃាត់ឃដិការស្មូនឆ្នាំងអស់វារៈ ៣ ដង ដូច្នេះថា កុំឡើយឃដិការសម្លាញ់ស្មោះស្មើចិត្ត ចុះអ្នកឯងចង់គាល់ស្រមណ៍កំណោរនោះបានជាការអ្វី។ ឃដិការស្មូនឆ្នាំងតបថា នៃជោតិបាលសម្លាញ់ស្មោះស្មើចិត្ត បើដូច្នោះ យើង

នឹងកាន់យកខ្សែអំបោះសោត្តី[១] សម្រាប់ផ្លូតទឹកទៅកាន់ស្ទឹងដើម្បីផ្លូតទឹក។ ម្នាលអានន្ទ ជោតិបាលមាណពបានទទួល ពាក្យឃដិការស្មូនឆ្នាំងថា យ៉ាងហ្នឹងហើយសម្លាញ់ស្មោះស្មើចិត្ត ។

ម្នាលអានន្ទ លំដាប់នោះ ឃដិការស្មូនឆ្នាំងនឹងជោតិបាលមាណព ក៏នាំគ្នាយកខ្សែអំបោះសោត្តី ទៅកាន់ស្ទឹងដើម្បីផ្លូតទឹក។ ម្នាលអានន្ទ គ្រានោះ ឃដិការស្មូនឆ្នាំង និយាយនឹងជោតិបាលមាណពថា ម្នាលជោតិបាល សម្លាញ់ស្មោះស្មើចិត្ត នេះហើយអារាមរបស់ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធនៅជិតបង្កើយទេតើ នៃជោតិបាលសម្លាញ់ស្មោះស្មើចិត្តមក យើងនឹងនាំគ្នា ចូលទៅគាល់ព្រះកស្សបមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ព្រោះថា ការបានឃើញព្រះ

---

១. ខ្សែអំបោះដែលគេយកលំអិតថ្មឈ្មោះកុរុវិន្ទកៈមកលាយនឹងល័ខ ហើយចងភ្ជាប់ត្រង់កណ្តាលខ្សែអំបោះ ទុកតែត្រង់ចុងខ្សែទាំងសងខាង សម្រាប់កាន់ដុសកាយក្នុងវេលាដែលផ្លូតទឹក។

មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ របស់ខ្ញុំ សន្មតថាជាការប្រពៃ។

ម្នាលអានន្ទ កាលបើយដិការស្នូនផ្ទាំងនិយាយ យ៉ាងនេះ ជោតិបាលមាណពក៏ឃាត់យដិការស្នូនផ្ទាំង ទៀតដូច្នេះថា កុំឡើយ យដិការសម្លាញ់ស្មោះស្មើចិត្ត ចុះអ្នកឯងចង់គាល់ស្រមណ៍ស្រមកំណោរនោះ បាន ជាការអ្វី។ ម្នាលអានន្ទ យដិការស្នូនផ្ទាំងនិយាយអស់ វារៈ២ដង ។បេ។ ម្នាលអានន្ទ យដិការស្នូនផ្ទាំង និយាយនឹងជោតិបាលមាណពអស់វារៈ ៣ ដងដូច្នេះ ថា ម្នាលជោតិបាល សម្លាញ់ស្មោះស្មើចិត្ត នេះហើយ អារាម របស់ព្រះកស្សបមានព្រះភាគ អរហន្ត សម្មាសម្ពុទ្ធ នៅជិតបង្កើយទេតើ ម្នាលជោតិបាល សម្លាញ់ស្មោះស្មើចិត្ត មក យើងនឹងនាំគ្នា ចូលទៅ គាល់ព្រះកស្សបមានព្រះភាគ អរហន្ត សម្មាសម្ពុទ្ធ ព្រោះថា ការបានឃើញព្រះមានព្រះភាគ អរហន្ត សម្មាសម្ពុទ្ធអង្គនោះ របស់ខ្ញុំ សន្មតថាជាការប្រពៃ ។

ម្នាលអានន្ទ ជោតិបាលមាណព ក៏ឃាត់ឃដិការស្មូនឆ្នាំងអស់វារៈ ៣ ដងដូច្នេះថា កុំឡើយ ឃដិការសម្លាញ់ស្មោះស្មើចិត្ត ចុះអ្នកឯង ចង់គាល់ស្រមណ៍កំណោរនោះបានជាការអ្វី ។

ម្នាលអានន្ទ គ្រានោះ ឃដិការស្មូនឆ្នាំងក៏ចាប់ទាញថ្នក់ជោតិបាលមាណព និយាយលោមដូច្នេះថា ម្នាលជោតិបាល សម្លាញ់ស្មោះស្មើចិត្ត នេះហើយអារាម របស់ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ នៅជិតបង្កើយទេតើ ម្នាលជោតិបាល សម្លាញ់ស្មោះស្មើចិត្ត មក យើងនឹងនាំគ្នាចូលទៅដើម្បីគាល់ព្រះកស្សបមានព្រះភាគ អរហន្ត សម្មាសម្ពុទ្ធ ព្រោះថា ការបានឃើញព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ របស់ខ្ញុំសន្មតថា ជាការប្រពៃ។ ម្នាលអានន្ទ ទើបជោតិបាលមាណព ឲ្យឃដិការស្មូនឆ្នាំងលែងកាន់ថ្នក់ ហើយនិយាយដូច្នេះថា កុំឡើយ ឃដិការសម្លាញ់ស្មោះស្មើចិត្ត ការឃើញ

ស្រមណ៍កំណោរនោះ បានជាការអ្វី។ ម្នាលអានន្ទ លំដាប់នោះ ឃដិការស្ទូនផ្ទាំង ក៏ចាប់ទាញសក់ជោតិបាលមាណព ដែលទើបនឹងផ្ងូតរួច ហើយនិយាយលោមដូច្នេះថា ម្នាលជោតិបាលសម្លាញ់ស្មោះស្មើចិត្តនេះហើយអារាម របស់ព្រះកស្សបមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ នៅជិតបង្កើយទេតើ ម្នាលជោតិ-បាលសម្លាញ់ស្មោះស្មើចិត្ត មក យើងនឹងនាំគ្នាចូលទៅគាល់ព្រះកស្សមមានព្រះភាគ អរហន្ត សម្មាសម្ពុទ្ធ ព្រោះថា ការបានឃើញព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ របស់ខ្ញុំសន្មតថា ជាការប្រពៃ។ ម្នាលអានន្ទ គ្រានោះ ជោតិបាលមាណពមានសេចក្តីត្រិះរិះដូច្នេះថា ឱហ្ន៎ អស្ចារ្យណាស់ ឃីអើចម្លែកណាស់ មិនសមបើឃដិការស្ទូនផ្ទាំង ជាមនុស្សមានកំណើតថោកទាបនេះ មកហ៊ានមើលងាយ ចាប់ទាញសក់របស់អញ ដែលទើបនឹងផ្ងូតហើយ ដូច្នេះសោះប្រហែលជាដំណើររបស់អញ ដែលនឹងទៅនេះ មិន

មែនជាដំណើរថោកទាបឡើយ។ ទើបជោតិបាល មាណពសួរឃដិការស្មូនឆ្នាំងដូច្នេះថា ម្នាលឃដិការ សម្លាញ់ស្មោះស្មើចិត្ត អ្នកឯងចាប់ទាញសក់ខ្ញុំដល់ត្រឹមណាទៅទៀត។ ឃដិការស្មូនឆ្នាំងតបថា នៃជោតិបាលសម្លាញ់ស្មោះស្មើចិត្ត ខ្ញុំចាប់ទាញសក់ អ្នកឯងទាល់តែខ្ញុំបានទៅគាល់ ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ ដែលសន្មតថា ជាការប្រពៃ។ ជោតិបាលមាណពតបថា នៃឃដិការសម្លាញ់ស្មោះស្មើចិត្ត ណ្ហើយ លែង យើងនឹងទៅដែរ។

ម្នាលអានន្ទ គ្រានោះ ឃដិការស្មូនឆ្នាំងនិងជោតិបាលមាណពនាំគ្នា ចូលទៅគាល់ ព្រះកស្សបមានព្រះភាគ អរហន្ត សម្មាសម្ពុទ្ធ លុះចូលទៅដល់ហើយឃដិការស្មូនឆ្នាំងក្រាបថ្វាយបង្គំព្រះកស្សបមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ហើយក៏អង្គុយក្នុងទីដ៏សមគួរ។ ឯជោតិបាលមាណពពោលពាក្យរាក់ទាក់សំណេះសំណាល ទៅរកព្រះកស្សបមានព្រះភាគ

អរហន្តសម្មាសម្ពុទ្ធ លុះបញ្ចប់ពាក្យ ដែលគួររីករាយ និងពាក្យដែលគួររលឹកហើយក៏អង្គុយក្នុងទីដ៏សមគួរ។ លុះឃដិការស្មូនឆ្នាំង អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូល ព្រះកស្សបមានព្រះភាគ អរហន្ត សម្មាសម្ពុទ្ធដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ជោតិ-បាលមាណពនេះ ជាមិត្តសម្លាញ់ពេញចិត្តនៃខ្ញុំព្រះអង្គ សូមព្រះមានព្រះភាគសំដែងធម៌ ប្រោសជោតិ-បាលមាណពនេះឲ្យទាន។

ម្នាលអានន្ទ គ្រានោះ ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ បានពន្យល់ឃដិការស្មូនឆ្នាំង និងជោតិបាលមាណព ឲ្យយល់ឃើញច្បាស់ ឲ្យជឿជាក់ ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា។ ម្នាលអានន្ទ ឃដិការស្មូនឆ្នាំង និងជោតិបាលមណព លុះព្រះកស្សបមានព្រះភាគ អរហន្ត សម្មាសម្ពុទ្ធ ពន្យល់ឲ្យយល់ឃើញច្បាស់ ឲ្យជឿជាក់ ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏ត្រេកអររីករាយ

ចំពោះភាសិត របស់ព្រះកស្សបមានព្រះភាគ អរហន្ត សម្មាសម្ពុទ្ធ រួចក្រោកចាកអាសនៈ ថ្វាយបង្គំលា ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ធ្វើ ប្រទក្សិណហើយ ក៏ចៀសចេញទៅ។

ម្នាលអានន្ទ លំដាប់នោះ ជោតិបាលមាណព សួរឃដិការស្មូនឆ្នាំងដូច្នេះថា ម្នាលឃដិការសម្លាញ់ ស្មោះស្មើចិត្ត អ្នកឯងកាលបើស្តាប់ធម៌នេះហើយ តើ អ្នកឯង នឹងចេញចាកផ្ទះ ចូលទៅកាន់ផ្នួសឬទេ។ ឃដិការស្មូនតបថា ម្នាលជោតិបាលសម្លាញ់ស្មោះស្មើ ចិត្ត អ្នកឯងក្រែងដឹងថា ខ្ញុំតែងចិញ្ចឹមមាតាមិតា ដែល ចាស់ងងឹតងងល់ដែរឬ។ ជោតិបាលមាណពតបថា ម្នាលឃដិការសម្លាញ់ស្មោះស្មើចិត្ត បើដូច្នោះ ខ្ញុំនឹង ចេញចាកផ្ទះចូលទៅកាន់ផ្នួស ។

ម្នាលអានន្ទ គ្រានោះ ឃដិការស្មូនឆ្នាំង និង ជោតិបាលមាណពនាំគ្នា ចូលទៅគាល់ព្រះកស្សបមាន ព្រះភាគអរហន្តសម្មាសម្ពុទ្ធ លុះចូលទៅដល់ហើយ

ថ្វាយបង្គំព្រះកស្សបមានព្រះភាគ អរហន្ត សម្មាសម្ពុទ្ធ ហើយ ក៏អង្គុយទីដ៏សមគួរ។ ម្នាលអានន្ទ លុះឃដិការ ស្មូនឆ្នាំងអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបទូលព្រះ កស្សបមានព្រះភាគ អរហន្ត សម្មាសម្ពុទ្ធដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ជោតិបាលមាណពនេះ ជា មិត្តសម្លាញ់ពេញចិត្ត របស់ខ្ញុំព្រះអង្គ សូមព្រះមាន ព្រះភាគបំបួសជោតិបាលមាណពនេះ ឲ្យទាន។ ម្នាល អានន្ទ ជោតិបាលមាណពក៏បាននូវបព្វជ្ជា បាននូវ ឧបសម្បទា ក្នុងសំណាក់ ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ។ ម្នាលអានន្ទ គ្រាកាលដែលជោតិ បាលមាណព បានឧបសម្បទាមិនយូរប៉ុន្មាន ទើបនឹង ឧបសម្បទាបានកន្លះខែប៉ុណ្ណោះ ព្រះកស្សបមានព្រះ ភាគអរហន្ត សម្មាសម្ពុទ្ធ ទ្រង់សម្រេចសម្រាន្ត ឥរិយាបថ ក្នុងវេភឡិគនិគមតាមសមគួរ ដល់ពុទ្ធ អធ្យាស្រ័យហើយ ទ្រង់ពុទ្ធដំណើរទៅ កាន់ចារិក សំដៅទៅកាន់ក្រុងពារាណសី កាលពុទ្ធដំណើរទៅ

កាន់ចារិកដោយលំដាប់ ក៏បានដល់ ក្រុងពារាណសី នោះ។

ម្នាលអានន្ទ ព្រះកស្សបមានព្រះភាគអរហន្ត សម្មាសម្ពុទ្ធទ្រង់រគង់នៅ ក្នុងឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសីនោះ។ ម្នាលអានន្ទ ព្រះរាជាដែន កាសីទ្រង់ព្រះនាម **កិកិ** បានឮដំណឹងថា ព្រះកស្សប មានព្រះភាគអរហន្តសម្មាសម្ពុទ ទ្រង់ពុទ្ធដំណើរ មក ដល់ក្រុងពារាណសីហើយ ឥឡូវទ្រង់គង់នៅក្នុងឥសិ បតនមិគទាយវ័នជិតក្រុងពារាណសី។ ម្នាលអានន្ទ វេលានោះ ព្រះរាជាដែនកាសីទ្រង់ព្រះនាម កិកិ បង្គាប់ រាជបុរសឲ្យរៀបចំយានដ៏ល្អៗ ហើយឡើងគង់យានដ៏ ល្អស្តេចចេញទៅអំពីក្រុងពារាណសី ដោយយានដ៏ ល្អៗ ដោយព្រះរាជានុភាពដ៏ប្រសើរ ដើម្បីគាល់ព្រះក ស្សបមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ លុះបរយានទៅ ទល់ត្រឹមទីដែលល្មមឈប់យានហើយ ក៏ចុះអំពីយាន ទ្រង់ស្តេចទៅដោយព្រះបាទទទេ ចូលសំដៅទៅគាល់

ព្រះកស្សបមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ លុះស្ដេចចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំ ព្រះកស្សបមានព្រះភាគអរហន្តសម្មាសម្ពុទ្ធរួចប្រថាប់ក្នុងទីសមគួរ។

ម្នាលអានន្ទ លុះព្រះរាជាដែនកាសីទ្រង់ព្រះនាម កិកិ ប្រថាប់ក្នុងទីសមគួរហើយ ព្រះកស្សបមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ក៏ទ្រង់ពន្យល់ឲ្យឃើញច្បាស់ ឲ្យជឿជាក់ ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា។ ម្នាលអានន្ទ លំដាប់នោះ ព្រះរាជាដែនកាសីទ្រង់ព្រះនាម កិកិ លុះព្រះកស្សបមានព្រះភាគជាអរហន្តសម្មាសម្ពុទទ្រង់ពន្យល់ឲ្យឃើញច្បាស់ ឲ្យជឿជាក់ ឲ្យអាចហាន ឲ្យរីករាយ ដោយនធម្មីកថាហើយក៏និមន្តព្រះកស្សបមានព្រះភាគ អរហន្ត សម្មាសម្ពុទ្ធសម្ពុទ្ធដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ព្រមទាំងភិក្ខុសង្ឃទទួលកត្ត របស់ខ្ញុំព្រះអង្គដើម្បីឆាន់ក្នុងថ្ងៃស្អែក។ ម្នាលអានន្ទ ព្រះកស្សបមានព្រះភាគអរហន្តសម្មាសម្ពុទ ក៏ទ្រង់ទទួលនិមន្ត ដោយ

តុណ្ហីភាព។ ម្នាលអានន្ទ គ្រានោះ ព្រះរាជាដែនកាសី ទ្រង់ព្រះនាម កិកិ ទ្រង់ជ្រាបថា ព្រះកស្សបមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ទទួលនិមន្តហើយ ក៏ក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំ ព្រះកស្សបមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ធ្វើប្រទក្សិណ ហើយស្តេចចេញទៅ។ ម្នាលអានន្ទ កាលនោះ ព្រះរាជាដែនកាសីទ្រង់ព្រះនាម កិកិ លុះកន្លងរាត្រីនោះ ហើយក៏ត្រាស់បង្គាប់រាជបុរស ឲ្យចាត់ចែងខាទនីយភោជនីយាហារ ដ៏ផ្ចិតផ្ចង់ដោយស្រូវសាលី មានពណ៌លឿង ជាអង្ករបាយទន់ ជាវត្ថុប្រាសចាកពណ៌ខ្មៅ មានទាំងសម្លដ៏ច្រើន និងម្ហូបគ្រឿមដ៏ច្រើន ក្នុងព្រះរាជដំណាក់ របស់ព្រះអង្គរួចហើយ បង្គាប់រាជបុរស ឲ្យក្រាបទូលកត្តកាលចំពោះព្រះកស្សបមានព្រះភាគអរហន្តសម្មាសម្ពុទ្ធថា បពិត្រព្រះអង្គដ៏ចម្រើន កាលដល់ហើយ ភត្តក៏សម្រេចហើយ។

ម្នាលអានន្ទ វេលានោះ ជាវេលាបុព្វណ្ហសម័យ ព្រះកស្សបមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ទ្រង់ស្បង់ ប្រដាប់បាត្រនិងចីវរ ស្តេចចូលទៅកាន់ ព្រះរាជដំណាក់នៃព្រះរាជាដែនកាសីទ្រង់ព្រះនាម កិកិ ព្រមដោយភិក្ខុសង្ឃ លុះចូលទៅដល់ហើយ ទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ។ ម្នាលអានន្ទ សម័យនោះព្រះរាជាដែនកាសីទ្រង់អង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយខាទនីយភោជនីយាហារ ដ៏ផ្ចិតផ្ចង់ ដោយព្រះហត្ថានៃព្រះអង្គឯង ឲ្យឆ្អែតស្កប់ស្កល់។ ម្នាលអានន្ទ កាលបើព្រះរាជាដែនកាសីព្រះនាម កិកិ ជ្រាបថាព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធសោយរួចស្រេចហើយ លែងលូកព្រះហស្តទៅក្នុងបាត្រហើយ ក៏កាន់យកអាសនៈមួយទាបជាងហើយប្រថាប់ក្នុងទីសមគួរ។ ម្នាលអានន្ទ លុះព្រះរាជាដែនកាសីព្រះនាម កិកិ ប្រថាប់ក្នុងទីសមគួរហើយក៏ក្រាបបង្គំទូលព្រះកស្សបមានព្រះភាគអរហន្ត

សម្មាសម្ពុទ្ធដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគទ្រង់ទទួលគង់ចាំវស្សា ក្នុងក្រុងពារាណសីរបស់ខ្ញុំព្រះអង្គ ឯការបម្រើសង្ឃមានសភាពដូច្នេះនឹងមានមិនដាច់។ ព្រះកស្សបមានព្រះភាគត្រាស់ថា បពិត្រព្រះមហារាជ កុំឡើយ ព្រោះថាការនៅចាំវស្សា តថាគតនៅចាំរួចហើយ។ ម្នាលអានន្ទ ព្រះបាទកិកិក្រាបបង្គំទូលអស់វារៈពីរដង ។បេ។ ម្នាលអានន្ទ ព្រះរាជាដែនកាសីព្រះនាម កិកិ ក្រាបបង្គំទូលព្រះកស្សបមានព្រះភាគអរហន្តសម្មាសម្ពុទ្ធអស់វារៈ ៣ដង ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគទ្រង់ទទួលគង់ចាំវស្សាក្នុងក្រុងពារាណសី របស់ខ្ញុំព្រះអង្គ ឯការបម្រើសង្ឃមានសភាពដូច្នេះ នឹងមានមិនដាច់។ ព្រះកស្សបមានព្រះភាគត្រាស់តបថា បពិត្រព្រះមហារាជ កុំឡើយ ព្រោះថាការនៅចាំវស្សា តថាគតនៅចាំរួចហើយ។ ម្នាលអានន្ទ គ្រានោះ ព្រះរាជាដែនកាសីព្រះនាម កិកិ ជ្រាបថាព្រះកស្សបមានព្រះភាគអរហន្ត

សម្មាសម្ពុទ្ធមិន ទ្រង់ទទួលគង់ចាំវស្សា ក្នុងក្រុងពារា-ណសីរបស់អញដូច្នេះហើយ ទ្រង់ក៏មានព្រះចិន្តារាយមាយ ទ្រង់តូចព្រះហឫទ័យ។ ម្នាលអានន្ទ វេលានោះ ព្រះរាជាដែនកាសីព្រះនាម កិកិ ក្រាបបង្គំសួរព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ចុះបុគ្គលដទៃណាមួយដែលជាអ្នកបម្រើវិសេសជាងខ្ញុំព្រះអង្គទៅទៀត តើមានដែរឬទេ។

ថ្វាយព្រះពរមហារាជ មានជ្បិតនិគមមួយឈ្មោះវេភឡិគៈ ក្នុងនិគមនោះ មានស្មូនឆ្នាំងឃដិការ ឯឃិការស្មូនឆ្នាំងនោះឯង ជាឧបដ្ឋាក ជាអ្នកបម្រើដ៏ប្រសើរ របស់តថាគត បពិត្រព្រះមហារាជ មហាបពិត្រទ្រង់ជ្រាបថា ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធមិនទ្រង់ទទួលគង់ចាំវស្សា ក្នុងក្រុងពារាណសីរបស់ព្រះអង្គដូច្នេះ ហើយក៏មានព្រះចិន្តារាយមាយ ទ្រង់តូចព្រះហឫទ័យ ចំណែកសេចក្តី

រាយមាយចិត្ត និងការតូចចិត្ត របស់យជិការស្នូនផ្ទាំង នោះមិនមាន ក្នុងកាលឥឡូវនេះផង នឹងមិនមានតទៅផង បពិត្រមហារាជ ព្រោះថា យជិការស្នូនផ្ទាំងជាអ្នកដល់នូវព្រះពុទ្ធជាទីពឹង ដល់នូវព្រះធម៌ជាទីពឹង ដល់នូវព្រះសង្ឃជាទីពឹង បពិត្រមហារាជ យជិការស្នូនផ្ទាំង ជាអ្នកវៀរការសម្លាប់សត្វ វៀរចាកការកាន់យកនូវវត្ថុដែលគេមិនបានឲ្យ វៀរចាកការប្រព្រឹត្តខុសក្នុងកាម វៀរចាកការនិយាយកុហក វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ បពិត្រព្រះមហារាជ យជិការស្នូនផ្ទាំង ជាអ្នកប្រកបដោយសេចក្តីជ្រះថ្លា មិនកម្រើក ក្នុងព្រះពុទ្ធ ប្រកបដោយសេចក្តីជ្រះថ្លា មិនកម្រើក ក្នុងព្រះធម៌ ប្រកបដោយសេចក្តីជ្រះថ្លា មិនកម្រើក ក្នុងព្រះសង្ឃ ប្រកបដោយសីល ជាទីត្រេកអរនៃព្រះអរិយៈ បពិត្រមហារាជយជិការស្នូនផ្ទាំងមិនមានសេចក្តីសង្ស័យក្នុងទុក្ខ មិនមានសេចក្តីសង្ស័យ ក្នុងហេតុជាគ្រឿងកើត

ឡើងនៃទុក្ខ  មិនមានសេចក្តីសង្ស័យក្នុងធម៌ជាគ្រឿងរំលត់ទុក្ខ  មិនមានសេចក្តីសង្ស័យក្នុងសេចក្តីប្រតិបត្តិជាដំណើរដើម្បីទៅកាន់ទីរំលត់ទុក្ខ  បពិត្រមហារាជយដិការស្នូនផ្ទាំង  ជាអ្នកបរិភោគកត្តតែ  ១  ពេលប្រព្រឹត្តធម៌ដ៏ប្រសើរ ជាអ្នកមានសីល មានកល្យាណ-ធម៌ បពិត្រមហារាជ យដិការស្នូនផ្ទាំង ជាអ្នកលះបង់កែវមណីនិងមាស  ជាអ្នកប្រាសចាកមាស  និងប្រាក់បពិត្រមហារាជ យដិការស្នូនផ្ទាំង ជាអ្នកមិនជីកផែនដីដោយជំនីកផង  មិនកកាយផែនដីដោយខ្លួនឯង  តែងយកតែអម្រែកទៅរែកដីប្រាំងបាក់  ឬអាចម៍ដី  ដែលកណ្តុរកកាយមកធ្វើភាជន៍  ហើយប្រកាស (សេចក្តី) យ៉ាងនេះថា  ជនណាចង់បាន (ភាជន៍)  ចូរដាក់អង្ករមួយសំពៀត  ឬក៏សណ្តែកបាយមួយសំពៀត  ក្នុងទីនេះចុះ  ហើយចង់បានភាជន៍បែបណា  ចូរនាំយកភាជន៍នោះទៅចុះ  បពិត្រមហារាជ  យដិការស្នូនផ្ទាំងទៀងតែនឹងទៅកើត  ជាឱបបាតិក:កំណើត  ហើយ

បរិនិព្វានក្នុងទីនោះ មានសភាពជាអ្នកមិនត្រឡប់ចាក លោកនោះវិញ ជាធម្មតា ព្រោះអស់ទៅនៃឱរម្ភាគិយ-សំយោជនៈទាំង ៥ ។

បពិត្រមហារាជ សម័យមួយ តថាគតសម្រេច សម្រាន្តនៅក្នុងវេកឡិគនិយម។ បពិត្រមហារាជ គ្រានោះ តថាគតស្លៀកស្បង់ ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅកាន់ទី ដែលមាតាបិតា របស់ឃដិការស្មូនឆ្នាំងនៅ លុះចូលទៅដល់ហើយ ក៏និយាយនឹងមាតាបិតា របស់ឃដិការស្មូនឆ្នាំងដូច្នេះថា ចុះភគវៈ[១]នេះ ចេញទៅក្នុងទីណា។ មាតាបិតារបស់ឃដិការស្មូនឆ្នាំងក៏ទូលថា បពិត្រព្រះអង្គដ៏ចម្រើន ឧបដ្ឋាក របស់ព្រះអង្គ ចេញទៅបាត់ហើយ សូមព្រះអង្គយកបាយអំពីឆ្នាំងនេះ យកសម្លអំពីភាជន៍នេះទៅឆាន់ចុះ។ បពិត្រមហារាជ គ្រានោះ តថាគតក៏យក

---

១. ហៅតាមគោត្រ ព្រោះឃដិការស្មូនឆ្នាំងជាភគវគោត្រ។

បាយអំពីឆ្នាំង យកសម្លអំពីភាជន៍ ឆាន់រួច ក៏ក្រោក ចាកអាសនៈហើយចៀសចេញទៅ។ បពិត្រមហារាជ លំដាប់នោះ ឃដិការស្មូនឆ្នាំងចូលទៅជិតមាតាបិតា លុះចូលទៅដល់ហើយ ក៏សួរទៅមាតាបិតាដូច្នេះថា នរណាយកបាយអំពីឆ្នាំង យកសម្លអំពីភាជន៍ទៅ បរិភោគ ហើយក្រោកចាកអាសនៈ ចៀសចេញទៅ បាត់។ មាតាបិតាប្រាប់ថា ម្នាលកូន ព្រះកស្សបមាន ព្រះភាគអរហន្តសម្មាសម្ពុទ្ធយកបាយអំពីឆ្នាំង យក សម្លអំពីភាជន៍ទៅឆាន់រួច ហើយក្រោកចាកអាសនៈ ចៀសចេញទៅ។ បពិត្រមហារាជ វេលានោះ ឃដិការ ស្មូនឆ្នាំងមានសេចក្តីត្រិះរិះដូច្នេះថា អញពេញហៅ មានលាភ អត្តភាពជាមនុស្ស អញពេញហៅបាន ដោយល្អ (ព្រោះថា) ព្រោះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គស្និទ្ធស្នាល នឹងអញ ក្រៃពេកយ៉ាងនេះ។ បពិត្រមហារាជ គ្រានោះ សេចក្តី

សុខដែលកើតអំពីបីតិ មិនលះបង់យដិការស្ទូនផ្ទាំង អស់កន្ទះខែ មិនលះបង់មាតាបិតាអស់៧ថ្ងៃ។

បពិត្រមហារាជ សម័យនោះ តថាគតនៅក្នុងវេកឡិគនិគមនោះឯង។ បពិត្រមហារាជ គ្រានោះ តថាគតស្លៀកស្បង់ ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យហើយចូលទៅកាន់ទី ដែលមាតាបិតា របស់យដិការស្ទូនផ្ទាំងនៅ លុះចូលទៅដល់ហើយ ក៏សួរមាតាបិតា របស់យដិការស្ទូនផ្ទាំងដូច្នេះថា ចុះភគវៈចេញទៅក្នុងទីណា។ មាតាបិតាទូលថា បពិត្រព្រះអង្គដ៏ចម្រើន ឧបដ្ឋាករបស់ព្រះអង្គចេញទៅបាត់ហើយ សូមព្រះអង្គយកនំកុម្មាសអំពីកឡោបីនេះ យកសម្ងអំពីភាជន៍នេះឆាន់ចុះ។ បពិត្រមហារាជ ពេលនោះ តថាគតក៏យកនំកុម្មាសអំពីកឡោបី យកសម្ងអំពីភាជន៍ឆាន់រួចហើយ ក៏ក្រោកចាកអាសនៈ ចៀសចេញទៅ។បពិត្រមហារាជ លំដាប់នោះ យដិការស្ទូនផ្ទាំងចូលទៅជិតមាតាបិតា លុះចូលទៅដល់ហើយ ក៏សួរ

មាតាបិតាដូច្នេះថា នរណាយកនំកុម្មាសអំពីកឡោប៉ី យកសម្ងអំពីភាជន៍បរិភោគ ហើយក្រោកចាកអាសនៈ ចៀសទៅ បាត់។ មាតាបិតាប្រាប់ថា ម្នាលកូន ព្រះកស្សបមានព្រះភាគអរហន្ត សម្មាសម្ពុទ្ធយកនំកុម្មាស អំពីកឡោប៉ីយកសម្ងអំពីភាជន៍ឆាន់ រួចហើយក្រោក ចាកអាសនៈចៀសចេញទៅ។ បពិត្រមហារាជ វេលានេះឃដិការស្មូនឆ្នាំងមានសេចក្ដីត្រិះរិះដូច្នេះថា អញពេញហៅមានលាភ អត្តភាពជាមនុស្ស អញពេញហៅបានដោយល្អ (ព្រោះ) ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គស្និទ្ធស្នាលនឹងអញក្រៃពេកយ៉ាងនេះ។ បពិត្រមហារាជ គ្រានោះ សេចក្ដីសុខដែលកើតអំពីបីតិ មិនលះបង់ឃដិការស្មូនឆ្នាំង អស់កន្លះខែ មិនលះបង់មាតាបិតាអស់៧ថ្ងៃ។

បពិត្រមហារាជ មានកាលសម័យមួយតថាគតនៅក្នុងវេភឡិគនិគមនោះឯង។ សម័យនោះ កុដិក៏លេចភ្លៀង។ បពិត្រមហារាជ ពេលនោះ តថាគតប្រាប់

ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរនាំគ្នាទៅ អ្នកទាំងឡាយចូរដឹងនូវស្មៅ ក្នុងលំនៅ យដិការស្នូនផ្ទាំងចុះ។ បពិត្រមហារាជ កាលដែល តថាគតបង្គាប់យ៉ាងនេះ ភិក្ខុទាំងនោះ ក៏បានតបមក នឹងតថាគតដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ស្មៅក្នុង លំនៅនៃយដិការស្នូនផ្ទាំង មិនមានទេ គាត់មានតែ លំនៅដែលប្រក់ស្មៅប៉ុណ្ណោះ។ តថាគតតបថា ម្នាល ភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរនាំគ្នា ទៅរុះរើយក ស្មៅ (ដែលប្រក់) ផ្ទះរបស់យដិការស្នូនផ្ទាំង មកចុះ។ បពិត្រមហារាជ គ្រានោះភិក្ខុទាំងនោះក៏នាំគ្នារុះរើស្មៅ (ដែលប្រក់) ផ្ទះរបស់យដិការស្នូនផ្ទាំង។ បពិត្រមហា រាជ នៅវេលានោះ មាតាបិតារបស់យដិការស្នូនផ្ទាំង សួរភិក្ខុទាំងនោះដូច្នេះថា នរណារុះរើស្មៅ (ដែល ប្រក់) ផ្ទះ។ ភិក្ខុទាំងឡាយតបថា ម្នាលនាង កុដិរបស់ ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ លេច ភ្លៀង។ មាតារបស់យដិការស្នូនផ្ទាំងទូលថា បពិត្រ

លោកទាំងឡាយដ៏ចម្រើន ចូរលោកម្ចាស់ទាំងឡាយ នាំយកទៅចុះ បពិត្រលោកមានភក្ត្រ ដ៏ចម្រើនទាំងឡាយ ចូរលោកម្ចាស់ទាំងឡាយ នាំយកទៅចុះ។ បពិត្រមហារាជ គ្រានោះឃដិការស្ទូនផ្ទាំងចូលទៅជិតមាតាបិតា លុះចូលទៅដល់ហើយ ក៏សួរមាតាបិតាដូច្នេះថា នរណារុះរើយកស្មៅដែលប្រក់ផ្ទះ (អស់ទៅ) ។ មាតាបិតាប្រាប់ថា ម្នាលកូន បានឮថា កុដិរបស់ ព្រះកស្សបមានព្រះភាគ អរហន្ត សម្មាសម្ពុទ្ធលេចភ្លៀង។ បពិត្រមហារាជ ទើបឃដិការស្ទូនផ្ទាំងមានសេចក្តីត្រិះរិះដូច្នេះថា អញពេញហោ មានលាភអត្តភាពជាមនុស្ស អញពេញហោ បានដោយល្អ (ព្រោះថា) ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់ស្និទ្ធស្នាលនឹងអញក្រៃពេកយ៉ាងនេះ។ បពិត្រមហារាជ គ្រានោះ សេចក្តីសុខដែលកើតអំពីបីតិ មិនលះបង់ឃដិការស្ទូនផ្ទាំង អស់កន្លះខែ មិនលះបង់មាតាបិតាអស់៧ថ្ងៃ។ បពិត្រមហារាជ គ្រា

នោះឯង លំនៅនោះមានអាកាសជាគ្រឿងប្រក់អស់៣ ខែគត់ ប៉ុន្តែមិនលេចភ្លៀងទេ បពិត្រមហារាជឃដិការស្តូនផ្ទាំង ជាអ្នកមានសភាពដូច្នេះឯង។ ព្រះរាជាទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន ឃដិការស្តូនផ្ទាំងមានលាភមែន អត្តភាពជាមនុស្ស ឃដិការស្តូនផ្ទាំងបានដោយល្អមែន (ព្រោះថា) ព្រះមានព្រះភាគព្រះអង្គទ្រង់ស្និទ្ធស្នាលក្រៃពេកយ៉ាងនេះ។

ម្នាលអានន្ទ គ្រានោះ ព្រះរាជាដែនកាសីព្រះនាម កិកិ ក៏បញ្ជូនទូវអង្ករនៃស្រូវសាលី មានពណ៌លឿង ជាអង្ករបាយទន់ចំនួន៥០០វាហៈ[១]ផង គ្រឿងសម្ល៉ដ៏ល្មមនឹងអង្ករនោះផង (ទៅឲ្យ) ដល់ឃដិការស្តូនផ្ទាំង។ ម្នាលអានន្ទ គ្រានោះ រាជបុរសទាំងនោះក៏ចូលទៅរកឃដិការស្តូនផ្ទាំង ហើយនិយាយដូច្នេះថា បពិត្រអ្នកដ៏ចម្រើន ព្រះរាជាដែនកាសីព្រះនាម កិកិ បានបញ្ជូនអង្ករនៃស្រូវសាលីមានពណ៌លឿង ជាអង្ករ

---

១. ចំនួន ២ រទេះ ត្រូវជាមួយវាហៈ។ អដ្ឋកថា។

បាយទន់ចំនួន៥០០រាហៈផង គ្រឿងសម្ល៍ល្មមនឹង
អង្ករនោះផង (មកឲ្យ) អ្នកបពិត្រអ្នកដ៏ចម្រើន សូម
អ្នកទទួលយកនូវវត្ថុទាំងនោះចុះ។ ឃដិការស្ទូនផ្ទាំង
តបថា ព្រះរាជាព្រះអង្គមានកិច្ចច្រើន មានការងារ
ដែលត្រូវធ្វើច្រើនណាស់ហើយ (កុំបាច់ព្រះរាជទាន) ដល់ខ្ញុំ
ឡើយ វត្ថុទាំងនេះចូរថ្វាយដល់ព្រះរាជាវិញចុះ។

ម្នាលអានន្ទ ប្រហែលជាអ្នកមានសេចក្តីត្រិះរិះ
យ៉ាងនេះថា បុគ្គលដទៃទេ ដែលកើតជាជោតិបាល
មាណពក្នុងសម័យនោះ។ ម្នាលអានន្ទ ហេតុនេះ អ្នក
កុំគប្បីយល់ឃើញយ៉ាងនេះឡើយ តថាគតហ្នឹងឯង
ដែលកើត ជាជោតិបាលមាណព ក្នុងសម័យនោះ។
លុះព្រះមានព្រះភាគ ទ្រង់សំដែងសូត្រនេះ ចប់ហើយ
ព្រះអានន្ទមានអាយុក៏មានចិត្តរីករាយត្រេកអរចំពោះ
ភាសិតរបស់ព្រះមានព្រះភាគ។

ចប់ឃដិការសូត្រ។

(សុត្តន្តបិដក មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក រាជវគ្គ បិដកលេខ ២៤ ទំព័រ ២៤៤)

# ៤. នឡបានជាតក

(ដើមបបុសមានថ្នាំងមួយក្នុងនឡបានជាតក)

ព្រះសាស្តា កាលស្តេចចារិក ទៅក្នុងដែន កោសល ដល់ស្រុកមួយឈ្មោះ នឡកបានគ្រាម ទ្រង់គង់នៅក្នុងកេតកវ័ន ជិតនឡក បានបោក្ខរណី ទ្រង់ប្រារព្ធ ដើមបបុសទាំងឡាយ បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា **ទិស្វា បទមនុត្តិណ្ណំ** ដូច្នេះជាដើម ។

បានឮថា ក្នុងកាលនោះ ភិក្ខុទាំងឡាយមុជទឹកក្នុងស្រះបោក្ខរណី ឈ្មោះ **នឡកបានៈ** ហើយឲ្យពួកសាមណេរ ដកដើមបបុស ដើម្បីធ្វើបំពង់ម្ជុល ឃើញដើមបបុសនោះ ជាបំពង់រហូត (មិនមានថ្នាំង តាំងអំពីចុងដល់គល់) ទើបចូលទៅគាល់ ព្រះសាស្តាហើយទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គឲ្យ

សាមណេរកាន់យក ដើមបបុសទាំងឡាយមក ដើម្បីធ្វើបំពង់ម្សុល ដើមបបុសទាំងនេះ ជាបំពង់ មិនមានថ្នាំងតាំងអំពីគល់រហូតដល់ចុង តើព្រោះហេតុអ្វី?

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ នេះជាការអធិដ្ឋានក្នុងអតីត របស់តថាគត ហើយទ្រង់នាំយកអតីតនិទានមកសម្តែងដូចតទៅថា

បានឮថា ក្នុងកាលមុន ត្រង់ទីនោះជាព្រៃ ។ មានអារក្សទឹកមួយ តែងស៊ីមនុស្ស សត្វ ដែលចុះទៅក្នុងស្រះបោក្ខរណី (ក្នុងព្រៃ) នោះ ។ ក្នុងកាលនោះព្រះពោធិសត្វ ជាស្តេចស្វា មានទំហំប៉ុន សត្វរមាំងចោមរោមដោយពួកពានរ ៨ ម៉ឺនជាបរិវារ អាស្រ័យនៅក្នុងព្រៃនោះ ។ ស្តេចស្វានោះទូន្មានពួកពានរទាំងឡាយថា នែបាទាំងឡាយ ក្នុងព្រៃនេះ មានដើមឈើពុលខ្លះ មានស្រះបោក្ខរណីដែលកើតឯង មាន

អមនុស្សហ្មួងហែងរក្សាខ្លះ អ្នកទាំងឡាយ កាលទំពាស៊ីផ្លែ ឈើតូចធំដែលមិនធ្លាប់ស៊ី ឬកាលបើផឹកទឹកដែលមិនធ្លាប់ផឹក ត្រូវសួរខ្ញុំជាមុន ។ ពួកពានរទាំងនោះទទួលពាក្យថា សាធុ ហើយថ្ងៃមួយក៏ទៅដល់ទីដែលមិនធ្លាប់ទៅ ត្រាច់ទៅក្នុងទីនោះច្រើនថ្ងៃ កាលស្វែងរកទឹកផឹក បានឃើញស្រះបោក្ខរណីមួយ តែមិនហ៊ានចុះផឹកទឹក អង្គុយចាំការមករបស់ព្រះពោធិសត្វ ។ ព្រះពោធិសត្វមកដល់ហើយសួរថា នៃបាទាំងឡាយ ហេតុអ្វីទើបអ្នកទាំងឡាយមិនផឹកទឹក ?

ពួកពានរឆ្លើយថា ពួកខ្ញុំរង់ចាំការមក របស់លោក ។

ស្តេចស្វាពោលថា នៃបាទាំងឡាយ ពួកអ្នកធ្វើនេះល្អហើយ ទើបដើរច្លែលស្រះបោក្ខរណីនោះកំណត់ស្នាមជើង ឃើញតែស្នាមជើងដែលចុះទៅ មិន

ឃើញស្នាមជើងឡើងមក ព្រះពោធិសត្វដឹងថា ស្រះបោក្ខរណីនេះ មានអមនុស្សហួងហែង ដោយឥតសង្ស័យ ទើបពោលថា នែបាទាំងឡាយ អ្នកទាំងឡាយមិនផឹកទឹក ឈ្មោះថា ប្រពៃហើយ ដ្បិតស្រះ បោក្ខរណីនេះ អមនុស្សហួងហែង ។

ចំណែកអារក្សទឹកដឹងថា ពានរទាំងនោះមិនចុះ ក៏សម្តែងខ្លួន ជាបុគ្គលមានពោះពណ៌ខៀវ មានមុខពណ៌ស ដៃជើងពណ៌ក្រហមឆ្អិន មានរូបរាងគួរខ្លាចគួរខ្លាច ជ្រែកផ្ទៃទឹកឡើងមកពោលថា ព្រោះហេតុអ្វី ទើបពួកអ្នកអង្គុយ សូមចុះ ក្នុងស្រះបោក្ខរណីនេះ ផឹកទឹកចុះ ។ លំដាប់នោះ ព្រះពោធិសត្វសួរអារក្សទឹកនោះថា អ្នកជាអារក្សទឹកកើតនៅ ក្នុងស្រះនេះឬ ?

អារក្សទឹកឆ្លើយថា អើយើងកើតក្នុងស្រះនេះ ។

ព្រះពោធិសត្វសួរថា អ្នករមែងចាប់បុគ្គល ដែលចុះទៅក្នុងស្រះបោក្ខរណីនេះឬ ?

អារក្សទឹកឆ្លើយថា អើយើងចាប់ យើងមិនដោះលែងអ្នកណាមួយឡើយ ដោយហោច សូម្បីតែបក្សីដែលចុះក្នុងស្រះបោក្ខរណីនេះ ឯអ្នកទាំងអស់សោតយើងក៏នឹងទំពាស៊ី ។

ព្រះពោធិសត្វពោលថា ពួកយើងមិនឲ្យ អ្នកស៊ីពួកយើងឡើយ ។

អារក្សទឹកសួរថា អ្នកទាំងឡាយផឹកទឹកនេះមិនមែនឬ ?

ព្រះមហាសត្វឆ្លើយថា អើ ពួកយើងនឹងផឹកតែផឹក ដោយមិនធ្លាក់ក្នុងអំណាចរបស់អ្នក ។

អារក្សទឹកសួរថា បើដូច្នោះ ពួកអ្នកនឹងផឹកដូចម្តេច ?

ស្ដេចពានរឆ្លើយថា អ្នកសម្គាល់ថាយើងនឹងចុះផឹកទឹកឬ ដ្បិតថា ពួកយើងនឹងមិនចុះទៅទេ យើងនឹងឲ្យពានរទាំង ៨ ម៉ឺន កាន់កំណាត់ដើមបបុសមួយម្នាក់ផឹកទឹកក្នុងស្រះបោក្ខរណី របស់អ្នក ដូចផឹកទឹកដោយដើមឈ្ងូកដូច្នោះ កាលបើយ៉ាងនេះ អ្នកមិនអាចស៊ីពួកយើងបានឡើយ ។

ព្រះសាស្ដា កាលទ្រង់ដឹងច្បាស់ សេចក្ដីនេះទ្រង់ត្រាស់ជាព្រះសញ្ញូពុទ្ធហើយ ទើបត្រាស់ពីរបាទដំបូងនៃគាថានេះថា

**ទិស្វា បទមនុត្តិណ្ណំ, ទិស្វានោតរិតំ បទំ។**

**យើងឃើញស្នាមជើងដែលមិនឡើង ឃើញតែស្នាមជើងដែលចុះ ។**

សេចក្ដីនៃពាក្យរបស់គាថានោះ មានដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ស្ដេចស្វានោះ មិនបានឃើញ

ស្នាមជើងឡើងមក សូម្បីតែមួយ ក្នុងស្រះបោក្ខរណី នោះ បានឃើញតែស្នាមជើងចុះទៅប៉ុណ្ណោះ កាល ឃើញយ៉ាងនោះ គឺមិនឃើញស្នាមជើងឡើង ឃើញ តែស្នាមជើងចុះ ទើបដឹងថា ស្រះបោក្ខរណីនេះ មាន អមនុស្សហួងហែងពិត កាលចរចាជាមួយអារក្សទឹក នោះ ទើបពោលថា

**នឡេន វារឹ បិស្សាម ។**

*ពួកយើងនឹងផឹកទឹកដោយដើមបបុស ។*

សេចក្តីនៃបាទគាថានោះថា ពួកយើងនឹងផឹក ទឹក ក្នុងស្រះបោក្ខរណីរបស់អ្នក ដោយដើមបបុស ។

ព្រះមហាសត្វពោលបន្តទៀតថា

**នេវ មំ ត្វំ វធិស្សសិ។**

**(កាលធ្វើយ៉ាងនេះ) អ្នកនឹងសម្លាប់យើងមិនបាន ។**

មានសេចក្ដីអធិប្បាយថា កាលយើងនិងបរិស័ទផឹកទឹក ដោយដើមបបុស យ៉ាងនេះ អ្នកនឹងសម្លាប់យើងមិនបាន ។

ព្រះពោធិសត្វ កាលពោល យ៉ាងនេះហើយ ទើបឲ្យនាំដើមបបុស មួយដើមមក ពិចារណាដល់បារមីទាំងឡាយ ហើយធ្វើសច្ចកិរិយា យកមាត់ផ្លុំ ដើមបបុសក៏ក្លាយទៅជាបំពង់ តាំងអំពីគល់ រហូតដល់ចុង មិនមានថ្នាំងក្នុងទីណាមួយឡើយ ។ ព្រះពោធិសត្វឲ្យនាំដើមបបុសដទៃៗមក ហើយផ្លុំចែកហ្វូងស្វាទាំងឡាយដោយទំនងនេះ តែកាលធ្វើដូចពោលមកនេះ មិនអាចឲ្យសម្រេចបាន ព្រោះដូច្នោះ មិនគួរកាន់យកយ៉ាងនេះឡើយ ។ ចំណែកព្រះ

ពោធិសត្វ អធិដ្ឋានថា ដើមបបុសទាំងអស់ ដែលកើតជុំវិញស្រះបោក្ខរណីនេះ ចូរជាបំពង់ទាំងអស់ចុះ ព្រោះឧបចារៈ នៃប្រយោជន៍ របស់ព្រះពោធិសត្វទាំងឡាយ ជាសភាពក្រៃលែង ការអធិដ្ឋានរមែងសម្រេច ។ តាំងអំពីនោះមក ដើមបបុសដែលកើតជុំវិញស្រះបោក្ខរណីនោះ គ្រប់ដើម ក៏ពុំមានថ្នាំងជាបំពង់រហូតមក ។

ពិតហើយ ក្នុងកប្បនេះ ឈ្មោះថា បាដិហារិយ៍ដែលតាំងនៅអស់កប្ប មាន ៤ ប្រការ ។

សួរថា តើបាដិហារិយ៍ ៤ ប្រការនោះ ដូចម្តេច ?

ឆ្លើយថា គឺរូបទន្សាយក្នុងព្រះចន្ទ នឹងតាំងនៅអស់ មួយកប្ប ១ ស្ថានទីដែលភ្លើងរលត់ក្នុង វដ្តកជាតក ភ្លើងមិនឆេះក្នុងទីនោះអស់មួយកប្ប ១ ស្ថានទីដែលជាលំនៅ របស់ឃដិការស្មូនឆ្នាំង ភ្លៀងក៏មិន

ស្រក់ចំត្រង់ផ្ទះនោះ អស់មួយកប្ប ១ ដើមបបុសដែល តាំងនៅជុំវិញស្រះបោក្ខរណីនោះ ជាបំពង់តែមួយ អស់មួយកប្ប ១ ឈ្មោះថា បាដិហារិយ៍ដែលតាំងនៅ អស់កប្ប ។

ព្រះពោធិសត្វ កាលអធិដ្ឋាន យ៉ាងនេះហើយ ទើបអង្គុយកាន់ដើមបបុសមួយ ។ ចំណែកពួកពានរ ទាំង ៨ ម៉ឺន ក៏កាន់យកដើមបបុសមួយម្នាក់ៗ អង្គុយ ជុំវិញស្រះបោក្ខរណី ។ ក្នុងវេលាដែលព្រះពោធិសត្វ យកដើមបបុសបឺតទឹក ពានរទាំងនោះ ក៏អង្គុយត្រង់ មាត់ច្រាំងនៃស្រះនោះផឹកទឹកហើយផឹកទឹក ។ កាល ពានរទាំងនោះផឹកទឹកយ៉ាងនេះ អារក្សទឹកមិនអាច ចាប់ពានរសូម្បីតែមួយ ក៏ទោមនស្ស ហើយទៅកាន់ និវេសន៍របស់ខ្លួន ។ ចំណែកព្រះពោធិសត្វព្រមទាំង បរិវារ ក៏ចូលទៅកាន់ព្រៃវិញ ។

ព្រះសាស្ដាទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថាដើមបបុសទាំងឡាយនេះ ជាបំពង់តែមួយ ជាការអធិដ្ឋានក្នុងកាលមុន របស់តថាគតនោះឯង ។

ព្រះសាស្ដា បានទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់បន្តអនុសន្ធិ ប្រជុំជាតកថា

អារក្សទឹកក្នុងកាលនោះ បានមកជាទេវទត្ត

ពានរ ៨ ម៉ឺនក្នុងកាលនោះ បានមកជាពុទ្ធស័ទក្នុងកាលឥឡូវនេះ

ចំណែកស្ដេចពានរដែលឈ្លាសក្នុងឧបាយក្នុងកាលនោះ គឺ **តថាគត** នេះឯង ៕

(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ឯកកនិបាត សីលវគ្គ )